**BMI0135**

## សម្ភាសន៍ជាមួយឈ្មោះ គ្រឹង រិត ភេទប្រុស អាយុ៨៩ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហមៈ “កុមារកងចល័ត”
## ស្រុកកំណើតនៅភូមិជ្រោយសំរោង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## សព្វថ្ងៃរស់នៅភូមិជ្រោយក្តឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ហ៊ិន សុផានី
## ០១:០៣:៥៧
## ៣៧ទំព័រ

ផានី ៖ ថ្ងៃនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ។ ខ្ញុំឈ្មោះ ផានី មកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយកន្លែងពួកខ្ញុំនឹង ចុះមកនេះគ្រាន់ចង់សាក់សួរពូពីប្រវត្តិពូ ដែលពូបានឆ្លងកាត់ពូសម័យខ្មែរក្រហម ។ ហើយរឿងរ៉ាវទាំងអស់នេះ ពួកខ្ញុំសុំយកមកចុះក្នុងទស្សនាវដ្ដីក៏ទុក ដូចជាប្រើប្រាស់សម្រាប់អ្នកស្រាវជ្រាវផ្សេងៗ ឲ្យបានដឹងពូរឿងប្រវត្តិសម័យខ្មែរក្រហមយ៉ាងម៉េច ក៏ទុកដូចឲ្យកូនក្មេងៗជំនាន់ក្រោយ បានរៀនសូត្រយល់ពីសម័យនឹងដែរ ។ ជាដំបូងខ្ញុំសុំអនុញ្ញាតិពូថតជារូបថត ក៏ដូចជាថតជាសម្លេងចឹងបានអត់?

រិត ៖ បានមានអី សម័យយើងនឹក និយាយឲ្យកូនក្មេងជំនាន់ក្រោយឲ្យស្គាល់រសជាតិថាយើងវាធ្វើបេះធ្វើចុះ អាងតែយើងមិនបានឃើញធ្វើក៏យើងបានចាស់ៗដូចថា ពីជំនាន់ខ្ញុំ ឬបងខ្ញុំឆ្លងកាត់មក ។

ផានី ៖ ចឹងពូមានឈ្មោះអីដែរ?

រិត ៖ ខ្ញុំឈ្មោះ រិត ។

ផានី ៖ អីគេរិត?

រិត ៖ ឈាន ។

ផានី ៖ ឈាន?

រិត ៖ ដាក់គ្រឹង រិតក៏បានដែរ ។

ផានី ៖ ឆ្នាំនឹងពូអាយុប៉ុន្មានហើយ?

រិត :	អូ! ឆ្នាំនេះក្បាល៨២ធំហើយ ចូល៩០ហើយ ៨៩ ។

ធានី :	៨៩?

រិត :	ហ្នឹង ។

ធានី :	ពូមានស្រុកកំណើតនៅណាដែរ?

រិត :	ខ្ញុំពីដើមមិញនៅប៉ោយសំរោង ដល់បានប្រពន្ធសម័យប៉ុលពតមក ជម្លៀសមកនៅនេះ ដល់បងប្អូនមកនៅនេះទាំងអស់មកនៅនេះប៉ោយក្លឿង ជាប់ ។

ធានី :	ស្រុកកំណើតពូនៅភូមិប៉ោយសំរោងចឹង?

រិត :	ហ្នឹងប៉ោយសំរោង ។

ធានី :	ឃុំអីដែរ?

រិត :	ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ។

ធានី :	សព្វថ្ងៃពូរស់នៅណាដែរ?

រិត :	នៅប៉ោយក្លឿង ។

ធានី :	ឃុំអីដែរ?

រិត :	ឃុំព្រះនេត្រព្រះដែរ ។

ធានី :	ឪពុកពូឈ្មោះអីគេ?

រិត :	ឈាន ។

ធានី :	អីគេឈាន?

រិត :	ស្អីឈាន ភ្លេច ដល់ជីតាស្លាប់ពីសង្គមចាស់ជំនាន់តូចៗ ខ្ញុំនៅតូចៗបានសួរម៉ែខ្ញុំបានដឹង ។

ធានី :	ពូអត់ដឹងដែរ?

រិត :	បាទ! ខ្ញុំភ្លេចអស់ហើយ ។

ធានី :	គ្រាន់ដឹងថាគាត់ឈ្មោះឈាន?

រិត :	បាទ! ឈាន ។

ធានី :	ហើយគាត់ស្លាប់ពេលណាដែរ?

រិត :	ឪគាត់នោះ ជីតាខ្ញុំ ។

ធានី :	ឪពុករបស់ពូ?

រិត :	អត់ទេ គាត់នៅសព្វថ្ងៃ នៅកំពង់ធំ ។

ធានី :	ចឹងគាត់រស់នៅកំពង់ធំ?

រិត : បាទ! បានប្រពន្ធនៅកាលសម័យយើងរដ្ឋប្រហារ ដែលពួកអាខ្មែរក្រហម គាត់រត់ចូលទៅយួន ។

ធានី : គាត់រត់ទៅវៀតណាម?

រិត : នោះវៀតណាម ។

ធានី : ហើយត្រឡប់មកទៅវិញ គាត់ទៅរស់នៅកំពង់ធំ?

រិត : ហ្នឹងហើយ នៅកំពង់ធំ បានប្រពន្ធចុងសព្វថ្ងៃ ម៉ែខ្ញុំបង្កើតនៅនោះ ។

ធានី : ចឹងគាត់ទៅរស់នៅកំពង់ធំវិញ?

រិត : បាទ! នោះឯង គាត់ឡើងទៅមកដែរតើ គាត់បាន២ឆ្នាំហើយ ដឹងយ៉ាងណា ។

ធានី : ចុះម្ដាយ?

រិត : ម្ដាយឈ្មោះ ប៊ួន ។

ធានី : អត់ដឹងអីប៊ួនទេ?

រិត : យាយប៊ួន ។

ធានី : គាត់នៅភូមិយើងនេះ?

រិត : នៅភូមិនេះឯងប៉ោយក្បៀង ។

ធានី : ពូមានបងប្អូនប៉ុន្មាននាក់?

រិត : ខ្ញុំបងប្អូន៦នាក់ ៧នាក់ ។

ធានី : ៧នាក់ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

រិត : ស្រី១ ស្រីស្លាប់បាត់ហើយ ។

ធានី : ស្លាប់ពេលណាដែរ?

រិត : ស្លាប់មិនបានម៉ានឆ្នាំផង ។

ធានី : ឆ្នាំ២០១០?

រិត : ឆ្នាំនោះ២០១០ ។

ធានី : ចុះប្រុស៦ នៅរស់ទាំង៦?

រិត : នៅរស់ទាំងអស់ ។

ធានី : ពូរៀបគ្រួសារនៅឆ្នាំប៉ុន្មានដែរ?

រិត : ខ្ញុំនោះ ឆ្នាំប៉ុន្មានចេះ រឿងឆ្នាំដូចជាវាភ្លេចអស់ខ្ញុំ ។

ធានី : វៀតណាមចូលយូរនៅ?

រិត ៖ ហ៎! វៀតណាមចូលយូរគ្រាន់ហើយ ។

ធានី ៖ កូនបងអាយុប៉ុន្មានទៅ?

រិត ៖ កូនបងនោះ ២២ ។

ធានី ៖ ចឹងអាចឆ្នាំ៨០ជាង ជិតចូល៩០ ។ ចឹងអាច៨៩ ៩០អី?

រិត ៖ នោះឯង ។ បើកូនបងខ្ញុំវា២១ ២២ហើយ ។

ធានី ៖ ៨៩ ៩០អាចពូរៀបការល្មមគាត់កើត ។

រិត ៖ បាទ!

ធានី ៖ ចឹងគ្រួសារពូឈ្មោះអីគេ?

រិត ៖ ឈ្មោះ គុល ចាន់ថុន ។

ធានី ៖ មានកូនប៉ុន្មាននាក់ដែរ?

រិត ៖ កូនទាំងអស់៧ ។

ធានី ៖ កូន៧ស្រីប៉ុន្មានប្រុសប៉ុន្មាន?

រិត ៖ ស្រី១នេះឯង ។

ធានី ៖ ដូចពូដែរ មានបងប្អូន៧ ស្រី១ ប្រុស៦ ដល់ពេលកូនមកស្រី១ប្រុស៦ដែរ ។

រិត ៖ បាទ!

ធានី ៖ ពូរៀនសូត្រដល់ណា?

រិត ៖ ពូកាលនោះដល់សម័យរដ្ឋប្រហារអត់មានបានរៀនទេ រត់ចុះរត់ឡើង ចុះអាយើងសម័យសង្គ្រាមយើងច្របូកច្របល់អាដែលនេះ ។ ថារៀនដូចយើងមិនបានរៀនទៅចុះ ។

ធានី ៖ កាលនឹងពូប្រាប់ដែរថា នៅសម័យខ្មែរក្រហមអាយុ១៨?

រិត ៖ បាទ!

ធានី ៖ ចឹងពូអាចជួយរៀបរាប់រឿងរ៉ាវអស់នឹងតាំងពីដំបូងទៅតាមអ៊ីដែលពូអាចចាំបាន?

រិត ៖ ដែលចាំបាន មានអីខ្ញុំ ពីដើមមិញ មានធ្វើអី យើងធ្វើស្រែៗ ដល់ពេញកម្លាំងលើកដីបាន គេឲ្យបញ្ជូនចូលចល័តកុមារលើកដីទំនប់របូតទល់ចប់ ។

ធានី ៖ កាលពេលពូចល័តកុមារដំបូងនៅណាវិញ?

រិត ៖ នៅភ្នំស្រេះ ។

ធានី ៖ នៅភ្នំស្រេះ?

រិត ៖ បាទ! នៅទំនប់ស្រេះយើង ។

ធានី ៖ ស្រះលិច ស្រះកើត?

រិត ៖ ស្រះកើតនេះ ពីស្រះទៅកំបោរ ។

ធានី ៖ ម៉េចទៀតពូ?

រិត ៖ លើកទំនប់របូតមកទល់ចប់នេះទេ ។

ធានី ៖ លើកទំនប់នៅកន្លែងណាទៅ?

រិត ៖ ចាប់ពីស្រះមកទល់នឹងកំបោរ ពីអូរលាចទៅទល់ស្នាច់ តាខែកយើង ទៅដល់ស្ពានស្រែង។ លើកអាងដែរ ។

ធានី ៖ ស្ពានស្រែង ឬត្រពាំងស្រែង?

រិត ៖ ស្ពានស្រែង ។

ធានី ៖ ទៅណាវិញ?

រិត ៖ ស្ពានស្រែងនៅនោះ ។

ធានី ៖ នៅក្បែរអាងត្រពាំងថ្ម?

រិត ៖ ទេ! ទៅនោះ ទៅកើតខាងជើងនោះវិញ ។

ធានី ៖ ស្ពានស្រែងទៅដល់ណាទៅ?

រិត ៖ ស្ពានស្រែងកាច់ធ្វើអានឹងរួចបានមកដល់នេះ មកដល់អាងត្រពាំងថ្មវិញ ។

ធានី ៖ ចឹងអាងគេដែរ?

រិត ៖ អាង។ដូចអាងរន្ទះបាញ់ដែរ ។

ធានី ៖ ចុះពូបានធ្វើការនៅទំនប់រន្ទះបាញ់នឹងអត់?

រិត ៖ ធ្វើ ខ្ញុំលើកដីលើកអីរួច ចប់ដាច់ស្រេចបិទវគ្គឆ្លងទៅអូរលាច ។ អាទំនប់អូរលាចធំទទឹងចេះនេះ ។ អូរលាចនៅខាងនោះភ្នំលាភនោះខាងកើតបៀតអូរលាភ ។

ធានី ៖ ព្រោះនៅកន្លែងភ្នំលាភមានតែអូរមួយទេ ហៅអូរលាភ កន្លែងស្ពាន?

រិត ៖ នេះឯងស្ពាន នោះហើយភ្នំ ពីដើមធំណាស់ មកដល់សព្វថ្ងៃរាបហើយ កំពស់៣ម៉ែត្រ ។

ធានី ៖ ចឹងកាលពេលពូនៅលើកទំនប់នឹង កាលពេលលើកទំនប់នឹង លើកទំនប់ពីភូមិយើងទៅពីត្រឹមអូររន្ទះបាញ់?

រិត ៖ ហ្នឹងអូររន្ទះបាញ់ទៅទល់នឹងកំបោរ ដល់រួចត្រង់នេះបិទវគ្គនេះរួច ទៅខាងអូរលាភម្តង ។

ធានី ៖ ហើយទៅស្នាច់ទៅអី?

រិត ៖ ហ្នឹងហើយស្នាច់ តាខែក ។

ធានី ៖ កន្លែងនឹងទំនប់ ឬប្រឡាយ?

រិត ៖ ទំនប់ ប្រឡាយ យើងស្រែប្រាំងស្រែអី ។

ធានី ៖ កន្លែងអូរវន្ទះបាញ់នឹង ទំនប់ ឬប្រឡាយ?

រិត ៖ ទំនប់ធំ ។

ធានី ៖ ចុះដល់ពេលកំប្លោរ?

រិត ៖ កំប្លោរ ២នាក់ទល់គ្នានឹងកំប្លោរ ទំនប់តែមួយនឹងឯង ។

ធានី ៖ តែគេហៅដាច់ៗចឹង?

រិត ៖ នោះឯង ។

ធានី ៖ វាមានទ្វារទឹកវាចេញមួយៗ?

រិត ៖ នោះឯង ។

ធានី ៖ ការងាររបស់ពូយ៉ាងម៉េចដែរ គេធ្វើយ៉ាងម៉េចទំនប់នឹង?

រិត ៖ ដូចខ្ញុំថាចឹង អារឿងម្ហូប រឿងបាយ រឿងបបរ វាមិនឲ្យយើងស៊ីឆ្អែត ។ មុនដំបូងវាមាន អី ដល់យូរទៅៗ គេថាវ៉ៃរបបអានេះចេញ របបដឹកម្មករកសិករ អ្នកមានអ្នកក្រម៉េច របបកសិករ អ្នកមានអ្នកក្រអីម៉េច សម័យរបបពីសម័យកាលនោះយួន គេជម្លៀសថ្មី ធ្វើ ការមិនល្អ យើងធ្វើបាន សម័យការនោះដូចដឹងស្រាប់ហើយ ។

ធានី ៖ មុនដំបូងពូនៅក្នុងភូមិធម្មតាទេ?

រិត ៖ ហ្នឹងហើយនៅក្នុងភូមិធម្មតា ។

ធានី ៖ អ្នកណាគេអ្នកមកហៅឲ្យទៅធ្វើ?

រិត ៖ នោះដូចថាយើងប្រធានភូមិប្រធានក្រុមគេៗបញ្ចូលគេរើសវ៉ៃពេញកម្លាំង ចូលចល័តកុមារ ចូលយូរៗទៅបានពេញបណ្ដោយ ពេញសិទ្ធិយុវជនបណ្ដោយ ។

ធានី ៖ កាលនឹងពេលពូចូលនឹង ប្រជាជនថ្មីមកភូមិនឹងនៅ?

រិត ៖ នៅៗតើ ធ្វើការជាមួយគ្នានៅភ្នំពេញនៅនេះ នៅអរិយក្សត្រ ភ្លេចឈ្មោះគ្នាអស់ហើយ នៅណាកំពត នៅជាមួយគ្នាធ្វើការជាមួយគ្នានៅស្រុកភូមិនេះនៅជាមួយគ្នាចំរុះគ្នា ។

ធានី ៖ កាលនឹងពូនៅជាមួយអ្នកថ្មីទាំងអស់?

រិត ៖ បាទ!

ធានី ៖ ហើយធ្វើការអីជុំគ្នាទាំងអស់?

រិត ៖ នៅជុំគ្នាទាំងអស់ ធ្វើការជាមួយគ្នាទាំងអស់ ។

ធានី ៖ ចឹងកុមារគេមានបែងចែកថ្មីចាស់?

រិត ៖ អត់ទេ អត់មានទេ ។

ធានី ៖ អត់បែងចែកទេ?

រិត ៖ អត់ទេ ចូលជាមួយគ្នាទាំងអស់ បើថាបាយក៏វាស់ម៉ាចានប៉ុននេះៗ អត់មានអ្នកចាស់បាយច្រើន អ្នកថ្មីបាយតិចមិនមានទេ ស្មើគ្នាទាំងអស់ ។ បើថាដល់អត់ពេញៗដឹង អត់នឹងត្រពាំងថ្មៗ ចានប៉ុននេះមិនបានចានប៉ុនគុយទាវយើងទេ តែវាទឹករៀងច្រើនតែ២-៣គ្រាប់ ។

ធានី ៖ មានបានបាយហូបទេ?

រិត ៖ គ្មានបានអីទេ កាលនោះ អាវីករៀងខ្លាំង កាលនេះខ្ទប់អានេះឯងបានខ្ញុំកាលនោះគេដកឲ្យ មកពួកចល័តកុមារ ។ កាលដកឲ្យធ្វើទំនប់ស្រែប្រាំងមួយក្រោមដល់ពេលនេះទៅវាបានធូរ កម្លាំងគ្រាន់ ដល់ពេលខ្យល់វារលកខ្លាំងខ្លាចបាក់ទំនប់ពួកខ្ញុំគេកំនែនឲ្យទៅកាប់ធាងដូង យកទៅខាន់កុំឲ្យខ្យល់វាបោកខ្លាំងខ្លាចបាក់ទំនប់ ធ្វើរួច ។

ធានី ៖ ទំនប់នៅណា?

រិត ៖ នៅស្ពានស្រែង ត្រពាំងថ្ម ។

ធានី ៖ ស្ពានស្រែងដង ត្រពាំងថ្មដង?

រិត ៖ នោះឯង ។

ធានី ៖ ចឹងចង់សួរពូថា កាលនឹងអ្នកណាគេហៅពូឲ្យចូលទៅកងចល័ត?

រិត ៖ កាលនោះវៃចោលឡើងចង់អស់ គ្នាវាវៃគ្នាវា ។

ធានី ៖ ឈ្មោះអីគេ?

រិត ៖ ប៉ិ-តូ ។

ធានី ៖ តូ?

រិត ៖ តូ ។

ធានី ៖ គាត់ជាប្រធានអីគេ?

រិត ៖ កាលនោះប្រធានក្រុម ។

ធានី ៖ ប្រធានក្រុមកុមារ?

រិត ៖ បាទ! ប្រធានក្រុមកុមារ ។

ធានី ៖ ប្រធានក្រុមកុមារនឹងជាអ្នកហៅ?

រិត ៖ ហៅដូចថាយើងប្រធានក្រុមនៅភូមិចេះយើងដក ថានាងឯងពេញកម្លាំងទៅដកទៅចូល ខ្ញុំពេញកម្លាំងដកទៅចូល កម្លាំងទី១ចេះ ទៅវិយកណ្ដាលដាក់តាមវិយកណ្ដាលដផ្ទៃគ្នា ជាមួយគ្នា ជាមួយរ័ត្នដែលនិយាយ គាត់នៅនោះកម្លាំងពេញ ។

ធានី ៖ ចឹងតូ នឹងជាប្រធានកងកុមារហៅពូប៉ុន្មាននាក់ ដែលជាកុមារនឹងទៅចូលក្នុងកងចល័ត?

រិត ៖ អូ! ច្រើនណាស់ វាដូចថាម៉ាឃុំព្រះនេត្រព្រះចេះ ក៏ហៅទាំងអស់នឹងទៅ ដូចថាម៉ាឃុំយើងប៉ុន្មាននាក់ ហៅបញ្ចូលគ្នា ធ្វើទាំងអស់គ្នាទៅ ។

ធានី ៖ ប៉ុន្មាននាក់ដែរពូ ស្មាន?

រិត ៖ អូ! ច្រើនណាស់ ដល់យូរយ៉ាងនេះ មានប៉ុន្មាននាក់ វាច្រើនណាស់រាប់រយនាក់ ។

ធានី ៖ ដូចថាមានអ្នកគ្រប់គ្រង?

រិត ៖ គ្រប់គ្រងពីលើធំគេនោះ មានតាវ៉ាល់ តាមោង១ ស្លាប់អស់ហើយ ។

ធានី ៖ តាមោងនឹង ជាអ្នកណាគេបានមកគ្រប់គ្រងនៅនឹង?

រិត ៖ ទេ! មិនដឹងស្រុកណាស្រុកណែ គាត់និយាយចឹង១ដែរ ។

ធានី ៖ គាត់មានឈ្មោះជាអី ពូដឹងទេ?

រិត ៖ មិនដឹងទេ ។

ធានី ៖ តែគ្រាន់ដឹង អ្នកស្រុកយើងដែរ?

រិត ៖ ទេ! គាត់អ្នកកាន់ក្ដាប់ដូចថាម៉ាទំនប់នៅលើគាត់ទាំងអស់ ។ ប៉ុនមិនដឹងគាត់ទៅនៅស្រុកណា១ ។

ធានី ៖ តែពូដឹងឈ្មោះគាត់ផ្សេងក្រៅពីនឹង ជាឈ្មោះអី?

រិត ៖ អត់ដឹងទេ ។

ធានី ៖ អត់ដឹងតាមោងនឹង ឈ្មោះជាអី?

រិត ៖ អត់ទេ ។

ធានី ៖ គ្រាន់ដឹងថាគាត់អ្នកកាន់ក្ដាប់នៅទំនប់ទាំងអស់ ដែលបានធ្វើ?

រិត ៖ នោះឯង ។

ធានី ៖ ហើយតាវ៉ាល់នឹង អ្នកកាន់ក្ដាប់ដែរ?

រិត ៖ នោះឯង តាវ៉ាល់ តាមោង ជាមួយគ្នា គូដៃគាត់ ។

ធានី ៖ ពួកគាត់កាចទេ?

រិត ៖ មិនបាច់និយាយ សម័យកាលនោះដឹងស្រាប់ហើយ គ្មានថាបន្ទាត់ បន្ទុមិនមានទេ ទាំងខ្មែរៗ ខ្ញុំប្រាប់ទៅ អាបាតអាងទំនប់នឹងអាងនេះមិនតិចទេ ។

ធានី ៖ បាតទំនប់អាងណា?

រិត ៖ អាងត្រពាំងថ្មនេះ វ៉ៃកប់ អាងត្រពាំងថ្មអាងនេះ វ៉ៃកប់ទាំងយុវជនយុវនារី ទាំងខ្មែរៗ ក្រុមកុមារដូចពួកខ្ញុំមិនសូវមានខូចខាតប៉ុន្មានទេ ជាពិសេសគ្នាវ័យកណ្ដាល ។

ធានី ៖ វ័យកណ្ដាលនឹងយ៉ាងម៉េច ត្រឹមណាៗ?

រិត ៖ វ័យកណ្ដាលដូចយើងមានប្ដី មានប្រពន្ធ ។

ធានី ៖ អានឹងគេហៅកម្លាំងទីប៉ុន្មាន?

រិត ៖ អានឹងកម្លាំងទី១ ទៅមុនដំបូងដូចថាយើងបានប្ដីមានប្រពន្ធ មិនទាន់មានកូនមានចៅ ។

ធានី ៖ អានឹងគេហៅកម្លាំងទី១?

រិត ៖ ដូចកម្លាំងទី១ហើយ ។ ដូចខ្ញុំនេះ ពេញកម្លាំងដែរ តែហៅកម្លាំងទី២នៅកុមារ ។

ធានី ៖ ចឹងបើយុវជនអីក៏ក្នុងកម្លាំងទី១ដែរ?

រិត ៖ កម្លាំងទី១ ។

ធានី ៖ ដល់ពេលពូនៅកម្លាំងទី២?

រិត ៖ កម្លាំងទី២កងកុមារ ។

ធានី ៖ ចឹងកម្លាំងទី១នឹង គេវ៉ៃសម្លាប់ ធ្វើបាបច្រើន?

រិត ៖ អឺ! ធ្វើបាបច្រើន ។

ធានី ៖ ចុះមិញពូថាតាវ៉ាល់ៗនឹង អ្នកធ្វើ ឬអ្នកណា?

រិត ៖ ពូមិនដឹងរឿងទេ ។

ធានី ៖ ខ្ញុំសួរថា តាវ៉ាល់នឹងកាចអត់?

រិត ៖ កាច ថាមិនកាច ពួកគាត់ ។

ធានី ៖ កាចយ៉ាងម៉េច? រូបរាងគាត់យ៉ាងម៉េច ពូដែលឃើញ?

រិត ៖ មាឌធំដំបងខ្មៅ ។

ធានី ៖ តាវ៉ាល់?

រិត ៖ តាវ៉ាល់ តាមោង,

ធានី ៖ តាមោងនឹង មាឌម៉េចដែរ?

រិត ៖ តាមោងនឹង មាឌគេធំរាងរអាញគ្រាន់ដែរ គ្រាន់ទាបជាងតាវ៉ាល់តិច ។

ធានី :	សំបុរ?

រិត :	សំបុរសណ្តែកបាយ ។

ធានី :	សណ្តែកបាយទាំង២?

រិត :	ហ្នឹងឯង ។

ធានី :	ដឹងពួកគាត់មកពីស្រុកណា?

រិត :	មិនដឹងទេ ដឹងគាត់មកពីស្រុកណា ស្រុកណែទេ អាពួកយើងនិរតី ។

ធានី :	តាវ៉ាល់នឹង?

រិត :	ហ្នឹងឯង ។

ធានី :	ចឹងកាលមុនពេលពូធ្វើនឹង មានអ្នកណាផ្សេងគ្រប់គ្រងក្រៅពីតាវ៉ាល់ តាមោងទេ?

រិត :	ទេ! គ្រាន់ពួកខ្ញុំចូលចល័តកុមារ ឃើញតែពួកគាត់នឹង កាន់របូត ទៅដល់ត្រពាំងថ្ម ត្រពាំងអី គាត់ទៅចល័តទៅតាមទៅចុះ ។

ធានី :	ប៉ុន្តែពេលនឹងតាមោង នៅតាមតាវ៉ាល់ទៀតអត់?

រិត :	តាមតែគ្នាគាត់ចុះ តាមដូចថាពួកគាត់កម្លាំងទី១ កម្លាំងទី២ គាត់ទៅត្រួតពិនិត្យមើលរាល់ថ្ងៃ បំបែកគ្នាទៅ ។ ដើរមើល ដាក់មុខងារយើងដើរមើលធ្វើជាប់មិនជាប់ ឲ្យធ្វើម្តងទៀតគំរង់អីចេះចុះ ។ បានគាត់ទៅនេះទៅនោះទៀតទៅ ។ ខ្ញុំនៅសម័យកាលនោះ នៅកុមារមិនសូវមានគ្រោះថ្នាក់ប៉ុន្មានទេ យ៉ាប់រឿងវ័យកណ្តាល១ ស្លាប់ច្រើនណាស់ វ័យកណ្តាល ។

ធានី :	ពូបានឃើញផ្ទាល់ភ្នែកទេ?

រិត :	អឺ! កាលនោះផ្ទាល់ភ្នែកនោះ ផ្ទាល់ទៅហើយ មានអាចឲ្យវ៉ៃខុសសីលធម៌វ៉ៃមនុស្សក៏មាន ដល់យើងនិយាយវាមិនរួច ។

ធានី :	យ៉ាងម៉េចចង់ប្រញាញ់ម៉េច ខុសសីលធម៌?

រិត :	ដូចថា បន្តោលមួយចេះ យើងសង់បន្តោលមួយចង នាងឯងស្រឡាញ់គ្នាចេះ ក៏ចងទៅកាត់ទោសសម្លាប់ចោល វ៉ៃដូង១ ។

ធានី :	គេយកទៅណា?

រិត :	វ៉ៃដូង១ផាប់កប់ក្លាម ។

ធានី :	កប់នៅនឹងមុខយើងនឹង?

រិត :	នឹងឯង ទេ! គេអូសរទេះយកទៅកប់តាមដៃ តាមព្រៃតាមអី ។

ធានី :	កាលនឹងពូស្គាល់ឈ្មោះ អត់ដែលខុសសីលធម៌នឹងទេ?

រិត ៖ អូ! មិនស្គាល់ទេ ខ្ញុំរីយកណ្តាលនារី ។

ធានី ៖ សម្លាប់តែនារីទេ ទាំងបុរសដែរ?

រិត ៖ សម្លាប់ទាំង២នាក់ ។

ធានី ៖ គេប្រាប់ប្រកាសចឹងថា ខុសសីលធម៌ចឹង?

រិត ៖ ហ្នឹងហើយខុសសីលធម៌ ។

ធានី ៖ នៅណាវិញ ដែលពូបានឃើញចឹង?

រិត ៖ នៅអូររន្ទះបាញ់ ទៅខាងនោះ ទៅខាងក្រាំងកើតដើមថ្កូវ ។

ធានី ៖ អានឹងគេព្រមានពួកយើងទាំងអស់គ្នា ។ អ្នកណាគេអ្នកសម្លាប់អី ពូដឹង?

រិត ៖ មិនស្គាល់គេទេ កាលខ្ញុំនៅមុខគេមិនហ៊ានមើលគេផង សម័យកាលនោះ ។

ធានី ៖ អត់ដឹងឈ្មោះគេ?

រិត ៖ អត់ដឹងទេ ។

ធានី ៖ គ្រាន់ដឹងថាសម្លាប់?

រិត ៖ ហ្នឹងហើយរកបណ្តាក់រឿងតែខ្លួន ព្រោះបើនិយាយតែពីនេះថាអស់កម្លាំង គ្រាន់តែលួចតែក្តិបចេកស៊ីក៏វារករឿងដែរ វេទនាណាស់ ។

ធានី ៖ អ្នកខុសសីលធម៌នឹងមកពីណាវិញ អ្នកស្រុកយើងឬក៏?

រិត ៖ ចល័តនឹងឯង អានេះចំរុះដឹងមកពីណាមកពីណៃ ចំរុះយើងធ្វើការទាំងអស់គ្នាទៅដូចថាម៉ាស្រុកព្រះនេត្រព្រះចេះ មិនដឹងថា នៅភូមិណាភូមិណៃអ្នកណាដឹងទេ មិនដឹងទេ ។ នៅសម័យកាលនោះ គ្មានអ្នកណាមើលមុខណាចំទេ ទោះបីស្គាល់គ្នាម៉េចគ្រាន់ថា មិត្តអើយទៅណា ។ ថាឲ្យបាយទឹកគ្នា គ្មានបាយទឹកណាចែកគ្នាស៊ី តែបងប្អូនបង្កើតដូចតែគ្នា ។

ធានី ៖ តែចង់សួរពូថា ពេលពូដំបូង ពូថាធ្វើការនៅភូមិយើងហើយបានគេចាប់ផ្តើមជ្រើសតាំងឲ្យ ទៅលើកទំនប់នៅរន្ទះបាញ់សិន?

រិត ៖ បាទ! នោះឯង ។

ធានី ៖ ហើយនៅតំបន់នឹង តើគេធ្វើការយ៉ាងម៉េចខ្លះ ហើយពូបានឃើញធ្វើអីខ្លះនៅទំនប់នឹងលើកដីយ៉ាងម៉េច?

រិត ៖ អូ! សុទ្ធតែវាស់ម៉ែត្រគីបហើយ ។

ធានី ៖ ប៉ុន្មានម៉ែត្រគីបដែលសម្រាប់ពូ?

រិត ៖ ខ្ញុំមុនដំបូងមួយម៉ែត្រ ផុតពីម៉ាម៉ែត្រគីប ដល់យើងធ្វើរួចពីថ្ងៃម៉ោង១០យើងលើករួច ដល់ យើងថ្ងៃក្រោយ គេតំលើងទៀតឡើងកន្លះម៉ែត្រគីបទៀត ។ ដល់ម៉ាម៉ែត្រគីបកន្លះលើករួច ថែមឲ្យ២ម៉ែត្រគីប រហូតទៅទល់២ម៉ែត្រគីបម៉ាថ្ងៃ ។ ម៉ាថ្ងៃចន់នាប់២ម៉ែត្រគីបកន្លះ ។

ធានី ៖ ២ម៉ែត្រគីបកន្លះទៀត?

រិត ៖ បាទ! ២ម៉ែត្រគីបកន្លះក្នុងម៉ាថ្ងៃ ដល់ចុងក្រោយ ។

ធានី ៖ ចុងក្រោយដែលថាចូលក្នុងកងតាវ៉ាល់នឹង?

រិត ៖ បាទ!

ធានី ៖ ចឹងពូពេលដែលចេញពីភូមិមក ទៅចូលកងតាវ៉ាល់ម៉ង ឬទៅណាទៀត?

រិត ៖ ចូលកងតាវ៉ាល់តែម្តង ។

ធានី ៖ ចុះអ្នកណាគេធ្វើប្រធានក្រុម?

រិត ៖ កាលនោះគេអ្នកថ្មី កាលនោះឈ្មោះអាស៊ុយ ។

ធានី ៖ អាស៊ុយនឹងជាអ្នកណា ជាប្រធានក្រុម?

រិត ៖ ប្រធានក្រុមម៉ារយៈដូចថាយើងទៅម៉ារួចម៉ាខ្សែប្រយុទ្ធ ដល់យើងចូលប្រយុទ្ធទី១ទៀត យើងប្រធានក្រុមទៀតខ្លះក៏មានដែរ ។ កាលណាបើយើងថា គេមិនបំបែកទេ ដើរជាប់ជាមួយគ្នា ក៏ប្រធានក្រុមដដែល ។

ធានី ៖ ចឹងកាលពេលពូទៅកងកន្លែងទំនប់រន្ទះបាញ់នឹង ប្រធានក្រុមឈ្មោះស៊ុយ?

រិត ៖ ស៊ុយ ។

ធានី ៖ ហើយគាត់កាចអត់?

រិត ៖ ទេ! ធម្មតាដូចយើងដូចគេ ។

ធានី ៖ ប៉ុន្មានៗពូដែល ឬមួយ?

រិត ៖ ទេ! ម៉ាសេរីគ្នា ដូចថាម៉ាក្រុម១០នាក់ៗ ។

ធានី ៖ ចុះមិញពូនិយាយថា អ្នកដែលខុសអីចឹងយកទៅសម្លាប់នៅទំនប់ម៉េច អត់ទាន់យល់អានឹង?

រិត ៖ យើងខុសសីលធម៌ បើថាសព្វថ្ងៃខុសប្រពៃណី យើងចេះពង្រត់ ចេះស្រឡាញ់គ្នា ។

ធានី ៖ តែ១នឹងទេ មានផ្សេងទៀតទេ ដែលពូបានឃើញ បានដឹង?

រិត ៖ ទេ! តែម៉ាគូប៉ុននោះឯង ផុតពីនោះមិនសូវមានទេ មានតែរឿងវៃចោលផ្សេងៗ ។

ធានី ៖ វៃចោលម៉េចខ្លះ?

រិត ៖ វៃចោលអារឿងដែលយើងវៃប្រហារគេ ថាយើងស៊ីបាយមិនឆ្អែតៗ អានឹងក៏មិនបាន ។

ធានី ៖ មិនបានដែរ?

រិត ៖ មិនបានទេ ។

ធានី ៖ ប៉ុន្មាននាក់ដែលពូបានឃើញ?

រិត ៖ អូ! កាលនោះដូចមានណា ក្អួយអើយគ្មានអ្នកណានឹងបានពិចារណាថាចេះចុះទៅគ្មានទេ មិន ហ៊ានទេ ។ ដូចថាយើងបើកតែភ្នែកចេះឯង នាំគ្នាមករបូត ។ បើដូចសព្វថ្ងៃ យើងនិយាយ តវ៉ាបាន ពីដើមមិញអ្នកណាហ៊ានទេ តែថាអានេះផ្តាច់ការ ។

ធានី ៖ ចង់សួរពូថា ពេលពូលើកទំនប់នៅ ព្រោះពូនៅកងតាវ៉ាល់ចឹង ជាកុមារចឹងមានការលំបាក អត់ពេលនៅរន្ទះបាញ់នឹង?

រិត ៖ អូ! អារឿងពិបាកៗហើយ ។

ធានី ៖ ពិបាកយ៉ាងម៉េច?

រិត ៖ ពិបាករឿងកម្លាំងយើងវាតូច យើងមុនដំបូងយើងថា ខំលើកម៉ាថ្ងៃបានម៉ាម៉ែត្រគីប ថា បាយរួចពីថ្ងៃ គេថាទោសម្រាកចុះដល់យើងលើករួចបានម៉ាអាទិត្យ ឡើងកន្លះម៉ែត្រគីប ។ ម៉ាម៉ែត្រគីបកន្លះ ដល់យើងរួចពីថ្ងៃឡើងទៀត ឡើងៗដល់បាន២ម៉ែត្រគីបកន្លះ ឡើងវាស់ ល្ងាចឡើងនៅ មិនងាយចេញចុះទេ មិនស្រួលបើនិយាយ វាចេញពីអន្ទង់ដីកដូចថាវាអស់ កម្លាំងពេញធឹង ។ យើងមានបានបាយណាស៊ីចេះចុះដូចសព្វថ្ងៃ មិនថាអញឃ្លានបាយទៅ ស៊ី មិនបានទេ ។ ដល់ពេលម៉ោងគេបានអាចទៅស៊ីបាន ។

ធានី ៖ កាលពេលពូនៅកងតាវ៉ាល់នឹង ដូចថាធម្មតាធ្វើការវាខ្លាំងជាងគេ ជាងឯងចឹង ហើយគេឲ្យ តែបបរហូប ។ខ្ញុំឮមីងគាត់និយាយប្រាប់ថា នៅទំនប់រន្ទះបាញ់នឹង វាពិបាកណាស់ ដោយ សារទឹកនឹងវាទប់មិនជាប់សោះ ដែលដឹងទេ?

រិត ៖ មិនដែលជាប់ទេ ។ នៅចំតួអាងដូចខ្ញុំថាចឹង ដែលវៃមនុស្សងាប់ច្រើនៗ ។ ពូបានដឹងរឿង នឹងដែរ នោះហើយ ។ វាវៃៗហើយ ប៉ុន្តែមិនដឹងប៉ុន្មាននាក់ៗទេ ។

ធានី ៖ ប៉ុន្តែដឹងថាច្រើន?

រិត ៖ ច្រើន ។

ធានី ៖ ហេតុអីបានគេវៃយកមកដាក់នៅកន្លែងអាងនឹង?

រិត ៖ ដូចថាយើងនិយាយ ដូចថាយើងស៊ីមិនឆ្អែត យើងចេះនិយាយបាតុភាពអីយើងទៅលួចទៅឆក់ទៅរកត្រី រកសាច់គេឃើញខុសពេលវេលាគេ ក៏មិនបាន ។

ធានី ៖ គេវៃយកដាក់លើទំនប់អាងវត្ដុះបាញ់នឹង?

រិត ៖ ចោលកប់ ទៅណាទៅណៃ ។

ធានី ៖ ចុះមិញពូមិននិយាយថា ទំនប់នឹងទប់ទឹកមិនជាប់ទេ ហើយមានទាក់ទងនឹងការសម្លាប់មនុស្សអស់នឹង?

រិត ៖ មិនដឹងដែរ ។ ខ្ញុំនៅវ័យកុមារចេះមិនសូវនេះទេ បើស៊េរីពួកគាត់បានច្បាស់ ។ បានគាត់មកផ្ទាល់ គាត់នៅចល័តទី១ នៅផ្ទាល់ហើយ ។

ធានី ៖ ប៉ុន្តែពូបានដឹងថា ដូចថាពេលទប់អត់ជាប់ចឹង គេយកមនុស្សយកមកដាក់នៅកន្លែងនឹង?

រិត ៖ អត់ទេ វាវៃចោល ដូចខ្ញុំថាមុនដំបូងចឹង វៃចោលកប់នោះដែរ ប៉ុន្តែវៃរួចកប់ដីនឹង ។

ធានី ៖ កប់ដីអាងនឹង?

រិត ៖ នៅលើកអាងកប់នឹងឯង ។

ធានី ៖ ដោយសារអត់មានកន្លែងកប់ ហើយយ៉ាងម៉េចបានគេយកមនុស្សទៅកប់នៅអាងនឹង?

រិត ៖ មិនដឹងជាថាអីរឿងកប់ ព្រៃប៉ុនណាប៉ុនណៃ ។

ធានី ៖ ចុះម៉េចអាងនឹងទប់ទឹកអត់ជាប់មកពីវាយ៉ាងម៉េច?

រិត ៖ ទឹកកាលនោះទឹកធំ យើងវាលើកកាត់អូរធំវែង សល់អាចម៍ដីជាង១០០ម៉ែត្រ ។

ធានី ៖ បើសិនជាទឹកធំចឹង ចាំបាច់យកមនុស្សទៅកប់នៅកន្លែងនឹងធ្វើអី?

រិត ៖ មិនដឹងទេ ។

ធានី ៖ ប៉ុន្តែដឹងថាមានគេកប់ទំនប់កន្លែងនឹង ដើម្បីបិទទឹក?

រិត ៖ហ្នឹងឯង ។

ធានី ៖ យកមនុស្សៗច្រើន អត់ដឹងប៉ុន្មាននាក់ទេ?

រិត ៖ មានប៉ុន្មាននាក់ មិនដឹងទេ ។

ធានី ៖ ហើយអ្នកនឹងមកពីណាខ្លះពូដឹងទេ?

រិត ៖ ដូចថាៗម៉ាស្រុកព្រះនេត្រព្រះ វានៅម៉ាកន្លែង មិនដឹងថាអ្នកមកពីខាងណាខាងណៃ ទាំងប្រជាជនចាស់ ទាំងប្រជាជនថ្មីទាំងអស់គ្នា ។

ធានី ៖ ទាំងអស់គ្នា?

រិត ៖ នោះឯង ។

ធានី ៖ អត់មានបែងចែកថា?

រិត ៖ គ្រាន់បែងចែកថា វ័យកណ្ដាលផ្សេង ហើយកម្លាំងនារីយុវជនផ្សេង ពួកចល័តកុមារផ្សេង ប៉ុននោះ គ្រាន់ម៉ាផ្នែកៗគ្នា ។ មានគេមិនឲ្យនៅជាមួយគ្នាច្របូកច្របល់ទេ វ័យកណ្ដាលមានប្ដីផ្សេង នារី យុវជនផ្សេង កុមារផ្សេង ។

ធានី ៖ ចឹងកាលពេលពូនៅធ្វើការនៅទំនប់អាងរន្ទះបាញ់នឹង បានហូបចុកគ្រប់គ្រាន់អត់?

រិត ៖ ទេ! មុនដំបូងមានអីគ្រប់គ្រាន់ ដល់យូរទៅៗ ដល់ធ្លាក់មែនទែនរបបមែនទែន យ៉ាប់មែនទែន ត្រពាំងថ្ម ។

ធានី ៖ ត្រពាំងថ្មបានយ៉ាប់?

រិត ៖ យ៉ាប់ហើយនោះ ។

ធានី ៖ បានអីហូបកាលពេលនៅអាងរន្ទះបាញ់?

រិត ៖ កាលនោះសម្ល បបរត្រកួន ។

ធានី ៖ តែបានហូបគ្រប់គ្រាន់?

រិត ៖ អឺ! អារឿងគ្រប់ម៉េចបានគ្រប់ ។

ធានី ៖ ចង់និយាយថា បានប៉ុន្មានពេលដែល ម៉ាថ្ងៃ?

រិត ៖ ម៉ាថ្ងៃនោះបាន២ពេលព្រឹកល្ងាច ។

ធានី ៖ ហើយយើងអាចរកអីហូបខាងក្រៅបានទេ?

រិត ៖ បាន ប៉ុន្តែកុំឲ្យគេឃើញៗអត់បានទេ ។ ឃើញរបស់នេះដាក់រួម បើគេកសាងមិនយកដាក់ រួមទេ ថ្ងៃក្រោយតែគេឃើញ ។

ធានី ៖ ដឹងនិយាយថាម៉េច?

រិត ៖ ដឹងនិយាយយ៉ាងណា ។

ធានី ៖ តែពូធ្លាប់ត្រូវបានគេចាប់បាន?

រិត ៖ ពួកខ្ញុំនោះៗអត់ដែរទេ ។

ធានី ៖ លួចកុំឲ្យគេដឹងម៉ង?

រិត ៖ បាទ! ទៅរកត្រី រកសាច់ដូចថាយើងរកស៊ី លើកដីលើកស៊ីនាំគ្នាទៅបាច់ទៅអីមានអីមកម៉ា ក្រុមចេះ ស្ងដាំស៊ីខ្លួនយើងខ្លះៗណាវាដោយកន្លែង ដោយមនុស្សដែរប៉ះណាប្រធានគេ នេះទៅឃើញបិទភ្នែកទៅណា គ្នាឯងប៉ុន្មាន៨-១០នាក់ដាំស្លហូតទៅផ្សេងៗ ។

ធានី ៖ ដាំស្លហូតអីបានដែរ?

រិត ៖ នោះឯង ហើយដូចថាយើងរកស្មុះក្រុមស្លខ្យងខ្ចៅ យកមកដុតស៊ីទៅមានអី ។

ធានី ៖ កាលពេលពូធ្វើនឹង ធ្វើពីពេលណាដែរ ទំនប់នៅរន្ទះបាញ់នឹង ដូចថាធ្វើពីពេលព្រឹកម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន ថ្ងៃឡើងម៉ោងប៉ុន្មានៗ?

រិត ៖ មានកំណត់វា ថ្ងៃដែលយើងមិនមានម៉ោងទេ មានម៉ោងតែគេ យើងស្មានមើលថ្ងៃថាម៉ោង ១០ម៉ោងអី គេឲ្យឡើងហូបបាយហើយ ។ ដល់ម៉ោង១ចាប់ផ្តើមទៀតហើយ ។ បើសិនដល់ពេលកម្លាំងដូចពួកវ័យកណ្តាល ដូចយុវជនអត់ទេណា៎ សម្រាកពេលតិចណាស់ ។ បើកុមារសម្រាកច្រើន ភាគច្រើនដែរ ។

ធានី ៖ សំខាន់ ឲ្យតែយើងធ្វើរួច គឺយើងអាចបានសម្រាក?

រិត ៖ សម្រាក បើយើងធ្វើមិនរួច គឺអត់បានសម្រាកទេ ។

ធានី ៖ ចឹងពូថាធ្វើនៅទំនប់រន្ទះបាញ់ហើយ ពូទៅកំបោរ?

រិត ៖ កំបោរ ។

ធានី ៖ កំបោរនឹងទំនប់ដែរ ឬមួយក៏ប្រឡាយ?

រិត ៖ ជាប់គ្នានឹងឯង ទំនប់ធំជាប់គ្នា ដល់អូរលាភក៏ទំនប់ប៉ុនគ្នា ។

ធានី ៖ តាមពិតទំនប់តែមួយ ទ្វារទឹកផ្សេងគ្នា?

រិត ៖ ផ្សេងគ្នានេះឯង ដូចថាម៉ាខ័ណ្ឌៗវា ។

ធានី ៖ ទំនប់នឹងគេហៅស្អីគេ?

រិត ៖ អានេះចាប់ពីនេះគេហៅទំនប់រន្ទះបាញ់ អានោះគេហៅទំនប់កំបោរ ម៉ាខ័ណ្ឌៗម្នាក់ ។

ធានី ៖ ប៉ុន្តែឧទាហរណ៍ដូចនៅត្រពាំងថ្មចឹង វាមានទំនប់ធំមួយចឹង វាមានភូមិឃុំអីផ្សេងៗគ្នាចឹង?

រិត ៖ នោះឯង ។

ធានី ៖ តែកន្លែងទំនប់ពូ ហៅទំនប់ត្រពាំងថ្មដែរ តែគ្រាន់មានភូមិឃុំផ្សេងគ្នា យ៉ាងម៉េច?

រិត ៖ អានេះទេ ទំនប់តួអាង ដូចយើងចេះឯង អានេះតួអូរ តួប្រឡាយធំចេះ ព័ទ្ធចេះឯង ។

ធានី ៖ តែអានឹងគេហៅដូចថានៅត្រពាំងថ្ម?

រិត ៖ ភូមិគេដល់ណាដល់ណោ ។

ធានី ៖ ចង់និយាយថា ត្រពាំងថ្មចឹង វាមានចឹងដូចពូនិយាយចឹង អានេះប្រឡាយ អូរ ភូមិជុំវិញនឹងអានឹងគេហៅទំនប់ត្រពាំងថ្ម?

រិត ៖ ហ្នឹងហើយទំនប់ត្រពាំងថ្ម ។

ធានី ៈ តែដល់ពេលដូចថាមិញ ពូថាទំនប់រន្ទះបាញ់ ទំនប់កំបោរអីចឹង វានៅអាកៀនចេះៗ ទូរ ទំនប់គេ ឬមួយយ៉ាងម៉េច ឬក៏វាតែមួយទេ?

រិត ៈ តែមួយអាងតែមួយ ។

ធានី ៈ អាងតែមួយនឹងឈ្មោះអាងអីគេ ពូដឹង?

រិត ៈ គេហៅអាងរន្ទះបាញ់ៗ ។

ធានី ៈ អាងរន្ទះបាញ់ ប៉ុន្តែវានៅដូចថានៅកន្លែងកំបោរ?

រិត ៈ នៅជាប់គ្នាចេះ ។

ធានី ៈ វាមានជាប់ប្រឡាយ?

រិត ៈ បាទ! ដល់នៅភូមិកំបោរ គេហៅទំនប់កំបោរទៅ គេថាតួអាងធំនៅរន្ទះបាញ់គេហៅរន្ទះ បាញ់ទៅ ទំនប់ស្រះមួយ គេហៅទំនប់ទៅ ។

ធានី ៈ និយាយទៅវាមានទំនប់មួយៗដាច់ៗ?

រិត ៈ នោះឯង ទេ!គ្មានដាច់ទេ តែវាជាប់គ្នា ប៉ុន្តែមានប្រឡាយ ។

ធានី ៈ គ្រាន់វាចេះទៅ មានប្រឡាយមួយហូរទៅ វាជាប់គ្នាតគ្នា?

រិត ៈ បាទ! នោះឯង ។

ធានី ៈ ចឹងកាលនៅទំនប់រន្ទះបាញ់នឹង ដឹងថាអ្នកណាគេ អ្នកប្រធាននៅនឹង?

រិត ៈ អូ! មិនដឹងទេ ។

ធានី ៈ ហើយមានប្រជាជនប៉ុន្មាននាក់ធ្វើការនៅនឹង?

រិត ៈ អូ! ច្រើនណាស់រាប់រយ រាប់ពាន់ អារឿងចល័តនោះ ។

ធានី ៈ ទំនប់នឹងកើតមុនត្រពាំងថ្ម ឬក៏ក្រោយ?

រិត ៈ ទំនប់នេះ ម៉ាស៊េរីគ្នានេះឯង ។

ធានី ៈ ម៉ាស៊េរីគ្នា?

រិត ៈ នេះឯង ។

ធានី ៈ តាមប្រឡាយ?

រិត ៈ តាមប្រឡាយនេះឯង ម៉ាស៊េរីគ្នា ។

ធានី ៈ អត់ដឹង អាមួយណាមុនអាមួយណាក្រោយ?

រិត ៈ ទេ!

ធានី ៈ ធ្វើដំណាលគ្នាទាំងអស់?

រិត ៖ ដំណាលគ្នាទាំងអស់របូត ។ ខ្ញុំធ្វើអានេះរួចបានចាប់ផ្តើមទៅធ្វើនោះ ឯងនោះគេលើកបន្ត ខ្ញុំលើកបន្តពួកគេទៅ ។

ធានី ៖ តាមការពិតពូលើកបន្តគ្នាដេញមុនៗរហូត?

រិត ៖ ទេ! ចាំមើលខ្ញុំនិយាយរយៈគ្នាចេះណា ខ្ញុំនៅនេះបុកទៅខាងកើតរន្ទះបាញ់ អ្នកពីកំពោរ បុកមកនេះទល់គ្នាមុខរន្ទះបាញ់ចេះ ។

ធានី ៖ ដើម្បីគួបគ្នាឲ្យឆាប់ហើយ?

រិត ៖ នោះឯងចេះឯង ។

ធានី ៖ ចុះអត់ដឹងថាអ្នកណាធ្វើទំនប់នឹង អ្នកកសាង?

រិត ៖ មិនដឹង កសាងនោះមិនដឹងទេ ។

ធានី ៖ អ្នករៀបចំគំនិតដើម្បីធើទំនប់នឹង អត់ដឹងទេ?

រិត ៖ អត់ដឹងទេ មិនដឹងរឿងទេ ។

ធានី ៖ អត់ដឹង ថាអ្នកណា អ្នកគ្រប់គ្រងការដ្ឋានទំនប់នឹងក៏អត់ដឹងដែរ?

រិត ៖ អត់ដឹងទេ ដឹងថាប្រធាន ។

ធានី ៖ ដឹងតែតាវ៉ាល់ ហើយនឹងតាមោង?

រិត ៖ បាទ! តាវ៉ាល់ តាមោង ។

ធានី ៖ ចឹងពេលពូទៅដល់ទំនប់កំពោរក៏ហូបចុកក៏ចឹងដែរ ហើយមានគេសម្លាប់មនុស្សដាក់ទំនប់ចឹង ដែរអត់ទេ?

រិត ៖ ទេ! ទៅដល់នោះ អត់សូវមាន ។

ធានី ៖ អត់សូវមាន ប៉ុន្តែរន្ទះបាញ់នឹងច្រើនជាងគេ?

រិត ៖ បាទ! រន្ទះបាញ់បានច្រើន ហើយឈឺស្លាប់ក៏ឈឺ ពិសេសឈឺកប់ចោលតាមព្រៃ ពេញណា ពេញណែ ចុះយើងមានពេទ្យមានអី ។

ធានី ៖ អត់មានពេទ្យ ។ ចុះពូធ្លាប់ឈឺដែរអត់?

រិត ៖ ខ្ញុំឈឺ ។

ធានី ៖ ឈឺពេលណាទៅ?

រិត ៖ អូ!ឈឺ ខ្ញុំឈឺកាលនោះឈឺសុំគេបានអីខ្ញុំទៅសុំគេបានដេកមកដេកពេទ្យនឹងឃុំ ក្នុងវត្តព្រះ នេត្រព្រះយើងសព្វថ្ងៃ អាលេបថ្នាំទន្សាយគេ អាមូលៗ ។

ធានី ៖ ពេលនឹងពូធ្វើការនៅណា បានមកដេកពេទ្យ?

រិត ៖ នៅទំនប់រនុះបាញ់យើង ។

ធានី ៖ ហើយឈឺប៉ុន្មានថ្ងៃទៅ?

រិត ៖ អួយ! ឈឺយូរគ្រាន់ណា ជិតចូលកន្ទុះខែដឹង ឈឺញាក់កាលនោះ ។

ធានី ៖ ហើយមានថ្នាំអីព្យាបាលដែរ?

រិត ៖ ខ្ញុំបានថ្នាំឫសឈើ អ៊ំខ្ញុំនៅគោកលន់ ។

ធានី ៖ គោកលន់?

រិត ៖ បាទ! នៅគោកលន់ អ៊ំខ្ញុំបង្កើត គាត់ស្លាប់ហើយ ។

ធានី ៖ ឈ្មោះអីគេអ៊ំនឹង?

រិត ៖ អ៊ំធួក ។

ធានី ៖ អ៊ំបង្កើត?

រិត ៖ អ៊ំបង្កើត ។

ធានី ៖ អ៊ំខាងម្តាយ ខាងឪពុក?

រិត ៖ ខាងម្តាយ កាលនោះគាត់ប្រធានសន្តមកិច្ច ដូចថាតាមភូមិតាមអីអ្នកណាឈឺអី គាត់ចេះតែ ជួយ មិនមានពេទ្យមានអីដូចយើងនេះទេ ។ គេហៅសន្តមកិច្ច ឫសឈើ ឫសអី ។

ធានី ៖ យ៉ាងម៉េចទៀតទៅ ដូចថាពេលពូធ្វើការចឹង ព្រោះពូនៅកងចល័តពិសេសចឹង កងរបស់ពូមានបាត់ខ្លួនបណ្តើរៗទេ ឬក៏នៅជុំគ្នារហូត?

រិត ៖ ទេ! កងពលខ្ញុំមិនអីទេ ប៉ុន្មានខ្ញុំ ម៉ាក្រុម៨-១០នាក់នេះ មិនបានអីទេនៅទាំងអស់ ។

ធានី ៖ ចុះប្រធានកងអីដែលគាត់នៅ?

រិត ៖ នៅជាមួយគ្នាទាំងអស់ដែរ ។

ធានី ៖ អត់ផ្លាស់ប្តូរទេ?

រិត ៖ អត់ទេ ឈ្មោះអាស៊ុយៗ ។

ធានី ៖ ហើយគាត់កាចអត់?

រិត ៖ ទេ! ធម្មតា គាត់ ។

ធានី ៖ ចឹងពេលពូទៅដល់អូរលាភ ការហូបចុកអីក៏អត់សូវអីដែរ?

រិត ៖ មិនសូវអីទេ ។

ធានី ៖ ការងារដូចនៅ?

រិត ៖ ដូចនៅនេះឯង នៅកំពោរ យ៉ាប់ៗស្ពានស្រែង អឺ! ត្រពាំងថ្ម ។

ធានី ៖ ចុះស្ពានស្រែង?

រិត ៖ ស្ពានស្រែងនោះមិនសូវយ៉ាប់ទេ ។

ធានី ៖ ត្រពាំងស្រែង ឬស្ពានស្រែង?

រិត ៖ ស្ពានស្រែង ។

ធានី ៖ ស្ពានស្រែង អត់សូវយ៉ាប់ទេ?

រិត ៖ មិនសូវយ៉ាប់ ។

ធានី ៖ តែស្ពានស្រែង កន្លែងគេធ្វើស្ពាន ឬមួយក៏យ៉ាងម៉េច?

រិត ៖ តួអាងដែរ ។

ធានី ៖ តែគេហៅស្ពានស្រែង?

រិត ៖ ប៉ុន្តែត្រពាំងថ្មនឹងធំជាងស្ពានស្រែង ។

ធានី ៖ ចឹងពូធ្វើស្ពានស្រែងហើយមកត្រពាំងថ្ម?

រិត ៖ មកត្រពាំងថ្ម ។

ធានី ៖ យ៉ាងម៉េចទៅត្រពាំងថ្មដំបូងដែលពូបានឃើញ?

រិត ៖ ត្រពាំងថ្មនោះ ដូចខ្ញុំថាចឹង ដូចជាអារឿងហូបចុកនេះពិបាកណាស់ អារឿងកម្លាំងពលះ បេះខំធ្វើហើយ ធ្វើម៉េចខំទៅ ។ ជាប្តេជ្ញាចិត្ត ក៏ម្នាក់ៗខំប្តេជ្ញាខ្លាចគេវៃចោល ។

ធានី ៖ ហើយកាលនឹង ពេលទៅដល់ទំនប់ដំបូងឃើញយ៉ាងម៉េចខ្លះ មានជាទំនប់ហើយឬនៅ ក៏នៅទេ?

រិត ៖ នៅៗ ពីដើម អាពីនេះគេមកហើយ តែយើងថាលើដល់គ្នានេះឯង គេលើកដល់នេះ យើងលើកមកនេះ យើងលើកបុកគ្នា ចាប់ដៃគ្នា ។

ធានី ៖ ចឹងកាលពេលពូលើកៗត្រឹមភូមិណា?

រិត ៖ ខ្ញុំលើកនៅពង្រ ។

ធានី ៖ នៅភូមិពង្រ?

រិត ៖ ភូមិពង្រ ។

ធានី ៖ អានឹងនៅក្នុងឃុំអីគេ?

រិត ៖ ឃុំភ្នំស្រុក ។

ធានី ៖ ឃុំភ្នំស្រុក?

រិត ៖ អឺ! ឃុំភ្នំស្រុកអី ស្រុកភ្នំស្រុក ឃុំអីគេជំនាន់នោះ ខ្ញុំខានដើរយូរទៅភ្លេចហើយ ។ សព្វថ្ងៃគេដាក់ឃុំអី អាស្រុកនេះ ស្រុកភ្នំស្រុក ។

ធានី ៖ ចង់និយាយថា ពូទៅលើកនៅពេលនឹង គឺដំបូងដីទទេរស្អាត ហើយពូចាប់ផ្ដើមលើក?

រិត ៖ ដីស្រែៗយើងធម្មតា ។

ធានី ៖ គេលើកយ៉ាងម៉េច ដីស្រែយើងធម្មតា?

រិត ៖ យកអាងធ្វើអាបណ្ដោយ ។

ធានី ៖ គេធ្វើយ៉ាងម៉េចខ្លះ ធម្មតាដីស្រែគេចឹង ហើយគេធ្វើម៉េចបានចេញជាអាង?

រិត ៖ លើកទំនប់ក្រវាត់រន្ទះបាញ់នេះឯង ដូចខ្ញុំថាតួចេះ ដូចថាតួពីដើមត្រពាំងថ្មៗពីដើមមិញធំត្រពាំងថ្មនេះជ្រៅណាស់ លើកក្រវាត់ចេះឯង ។ ដាក់ជើងត្បូងចេះ លើកក្រវាត់ចេះៗ ។

ធានី ៖ ហើយកាលពេលពូលើកប៉ុន្មានម៉ែត្រ ចាំទេ ថាប្រវែងវាដែលពូលើកនឹង?

រិត ៖ ដែលគេឲ្យដាក់ម៉ែត្រគីបនោះ ឬគិតគីឡូ ។

ធានី ៖ ទាំងអស់ ព្រោះធម្មតាពូធ្វើមិនមែនធ្វើម៉ាថ្ងៃប៉ុននឹង បានប៉ុននឹង ហើយឈប់ណា?

រិត ៖ អូ! អាធ្វើម៉ារួច ។ អូ! វែងដែរ ។ កាលនោះមិនដឹងជាប៉ុន្មានៗទេ គេឲ្យធ្វើ យើងគិតតែធ្វើ ។

ធានី ៖ ហើយតែកងពូ?

រិត ៖ នោះឯង ។

ធានី ៖ ធំទេ ប្រវែងវា?

រិត ៖ ធំណាស់ ទទឹង បើទទឹងខ្នងទំនប់ ខ្នងទំនប់នោះដឹងថា៥ម៉ែត្រហើយ ។

ធានី ៖ ៥ម៉ែត្រ ខ្នង?

រិត ៖ ខ្នង៥ម៉ែត្រហើយទំនប់ ។

ធានី ៖ ចុះកាលកងពូធ្វើៗប៉ុន្មាននាក់ទៅ?

រិត ៖ អូ! ធ្វើច្រើន ។

ធានី ៖ ហើយពូម្នាក់ ធ្វើប៉ុន្មានម៉ែត្រគីបក្នុងម៉ាថ្ងៃ?

រិត ៖ ២ម៉ែត្រគីបកន្លះ ។

ធានី ៖ ២ម៉ែត្រគីបកន្លះ សម្រាប់កងកុមារទេ?

រិត ៖ នោះហើយ អានោះពេញហើយ កំពុងពេញកម្លាំងហើយ កុមារត្រឹមម៉ាម៉ែត្រគីបៗកន្លះកាលនោះពេញហើយ ។

ធានី ៖ ហើយចឹងពេលពូលើកនឹង មានគេធ្វើម៉េចខ្លះ? ដំបូងដីរាបចឹង?

រិត ៖ យើងមានបង្គីរ ។

ធានី ៖ យើងជីកពីដីរាបនឹងទៅចាក់កន្លែងខាងម៉េច?

រិត ៖ ដូចថាយើងគេវាស់ឲ្យលើកពីម៉ែត្រគីបកន្លះចឹង ។

ធានី ៖ គេវាស់ហើយអស់ហើយ ឲ្យយើងជីក?

រិត ៖ វាស់ ដល់ព្រឹកឡើងប្រធានកង ប្រធានក្រុមគេវាស់ឲ្យរួចស្រេច បោះបង្គោលឲ្យស្រេច ដល់ហើយយើងបង្គីរ ដងរែក ចប ម្នាក់មួយៗ ។ បង្គីរនោះ អាបង្គីរល្អាក់យើងនោះឯង គេរែកធ្វើ ដូចយើងគេបញ្ចាំងឲ្យមើលតាមសម័យប៉ុលពត ។

ធានី ៖ បង្គីរធំ បង្គីរតូច?

រិត ៖ បង្គីរប៉ុនៗនេះ ។

ធានី ៖ ធំ?

រិត ៖ សព្វថ្ងៃរែកមិនរួចទេ ឃើញបង្គីរនឹង បង្គីរមកដាក់ម៉ាម៉ែត្រគីប តែ៣០-៤០អំរែកចង់បានម៉ាម៉ែត្រគីប ធំ ។

ធានី ៖ ប៉ុន្តែគ្រាន់លើកវាធ្ងន់ពេក?

រិត ៖ ធ្ងន់ បើវាថាបាតប្រឡាយនៅនេះ នោះដើមដូងចេះឯង រែកទៅចាក់ វាឆ្ងាយពីបាតប្រឡាយ ។

ធានី ៖ ហើយចាក់ដល់វាតួឡើងខ្ពស់?

រិត ៖ ទាល់ឡើងខ្ពស់ ។

ធានី ៖ ចឹងពូចាក់ធ្វើប៉ុន្មាន ដូចថាប៉ុន្មានខែ ប៉ុន្មានឆ្នាំ?

រិត ៖ ខ្ញុំនៅនឹងម៉ាខែកន្លះ ។

ធានី ៖ នៅនឹង?

រិត ៖ នោះហើយម៉ាខែកន្លះ ។

ធានី ៖ ម៉ាខែកន្លះធ្វើហើយ?

រិត ៖ អត់ទេ នៅមានកម្លាំងទី១គេធ្វើទៀត ដូចថាយើងមានធ្វើផ្លូវចេះ យើងធ្វើផ្លូវមិនល្អ មានកម្លាំងទី១គេបោសសំអាតទៀត ។ យើងដក ពួកខ្ញុំដកមកធ្វើអាប្រឡាយស្រូវប្រាំងប្រឡាយបង្ហូរទឹកតាមស្ពានទី១ អាស្ពានធំ ។

ធានី ៖ អានឹងគេហៅស្ពានអីគេ ពូដឹងទេ គេហៅស្ពានទី១?

រិត ៖ អានោះៗ គេហៅស្ពានទី១ គេមានស្ពានទី១ ស្ពានទី២ ស្ពានទី៣ ។

ធានី ៖ នៅនឹងមានស្ពានតែ៣ទេ?

រិត ៖ បាទ! ៣ ។ ម៉ាមុខអាងនោះមានស្ពាន៣ ។

ធានី ៖ មុខអាង ចុះនៅកាច់ជ្រុងអាងអី អត់មាន?

រិត ៖ អត់មានស្ពានទេ នៅសព្វថ្ងៃមានសម័យសព្វថ្ងៃ ហ៊ុន សែន យើងលើកអភិវឌ្ឍន៍បានមាន នោះ ពីដើមមិញគ្មានអីទេស ។

ធានី ៖ កាលមុនមានស្ពានតែ៣ទេ?

រិត ៖ បាទៗមានស្ពាន៣ ហើយប្រឡាយពោះគូចៗ ដែលគេធ្វើស្រែធ្វើភ្លឺនោះ ។

ធានី ៖ ចុះកាលពេលពួធ្វើនឹង ដូចថាមានចុះទឹក ត្រាំទឹក លើកទឹកអីទេ?

រិត ៖ ត្រាំទឹកនោះ ពីសម័យកាលនោះត្រាំហើយ តែវាខែវស្សា ។

ធានី ៖ ត្រាំទឹកម៉េច?

រិត ៖ ត្រាំទឹកដូចយើងសំរាកការងារ យើងមិនមានភូមិមានអី មានតែដេកនឹងទឹកក៏មានដែរ... ។

ធានី ៖ លើកទំនប់នៅណា?

រិត ៖ លើកអាភ្លឺ អាយើងធ្វើស្រែដែលយើងថាស វាហៅអី ដេក ។

ធានី ៖ តែកាលពេលនៅត្រពាំងថ្មនឹង អត់មានទឹកមានអីទេ?

រិត ៖ មាន ។

ធានី ៖ មានដែរ?

រិត ៖ មានដូចយើងមានទឹក ។

ធានី ៖ មានទឹកមកពីណា ក្រែងពូថាដីស្មើ?

រិត ៖ ទឹកធ្លាក់មកពីនោះ ។ ទឹកដីស្មើ ប៉ុនធ្លាក់មកពីខាង ភ្លូចគេហៅប៉ុស្តិ៍កើត ម៉ាជួរមកពី ភ្លូច ភូមិ ធ្លាក់មកពីខាងជើងនោះឯងទឹក ។

ធានី ៖ តែទឹកនឹង ម៉េចបានវាធ្លាក់មកកើត បើវាជាដីស្មើ ដូចតែយើងនៅដីស្មើយើងធម្មតា?

រិត ៖ ដីស្មើចេះឯង ប៉ុនដីរៀងដើរ វាជាក់ភ្នំព្រះនេត្រព្រះមក ធ្លាក់មកចេះ ។

ធានី ៖ ចឹងដីនឹងទាបជាងគេ?

រិត ៖ ទាបជាងគេ នឹងគេហៅអាងត្រពាំងថ្ម ចាស់បូរាណ ។

ធានី ៖ មានអាង កាលពីមុនមានអាងហើយ?

រិត ៖ ពីដើមមិញអត់ទេ គេហៅត្រពាំងថ្មៗដូចថាថ្មធំៗ ថ្មបូរាណពីជំនាន់ណាទេ ថ្មនឹងមានប៉ុន្មានផ្ទាំងដែរតើ ។

ធានី ៖ នៅយើងរាល់ថ្ងៃ?

រិត ៖ នោះនៅរាល់ថ្ងៃ នៅមកចេះទំនប់ ។ ដូចថាដឹងសម័យពីកាលណា សម័យឥស្សរៈ សម័យអីក៏មិនដឹងដែរ ។

ធានី ៖ ថាកន្លែងនឹងមានថ្ម?

រិត ៖ ថ្ម ។

ធានី ៖ ត្រពាំងនឹងវាសំបូរថ្មហើយម៉េច?

រិត ៖ សំបូរថ្មដូចវារៀងដុំប្រាសាទនោះ ថ្មធំណាស់ ។

ធានី ៖ ថ្មនឹងភាគច្រើននៅនឹង?

រិត ៖ ហ្នឹងហើយដូចថ្មបាយក្រៀម ។

ធានី ៖ ហើយនៅនឹងមានផ្លូវបូរាណអីដែរ?

រិត ៖ ផ្លូវមាន ។

ធានី ៖ ពេលពួទៅមានដែរ?

រិត ៖ មាន ។

ធានី ៖ ពេលពួទៅនឹងឃើញមានដែរ?

រិត ៖ មាន ។

ធានី ៖ ពេលយើងធ្វើ យើងបិទផ្លូវនឹង ឬយើងកាស់អានឹង?

រិត ៖ ទេ! កាត់ លើកកាត់អានោះ ។

ធានី ៖ លើកពីលើម៉ង?

រិត ៖ នោះឯង ។

ធានី ៖ អត់មានកាស់វាចេញ លើកកាត់ពីលើ?

រិត ៖ កាត់ទំនប់នោះឯង ។

ធានី ៖ លើកពីផ្លូវនឹង ផ្លូវនឹងធំទេ ផ្លូវនឹងព័ទ្ធជុំវិញអាង?

រិត ៖ ផ្លូវយើង ទេ!មិនមានផ្លូវទេ ដូចថាផ្លូវយើងទៅព្រៃ ផ្លូវមកចំការមកស្រែយើង ។

ធានី ៖ តែវាមានថ្មច្រើន?

រិត ៖ នោះឯង វាមានថ្ម ។

ធានី ៖ ហើយថ្មច្រើននឹង គេលើកដីពីលើថ្មនឹងម៉ង?

រិត ៖ បាទ!

ធានី ៖ អត់មានយកថ្មនឹងចេញទេ គឺលើកថែម?

រិត ៖ ទេ! បើចំក៏ចំទៅ អ្នកណាខុសបើ នៅម៉ាចំហៀងក៏នៅ។

ធានី ៖ បើចំ គាស់វាចេញ ឬក៏កប់?

រិត ៖ កប់ មិនមានអ្នកណាសួរលើកទេ។

ធានី ៖ តែពូបានប៉ះថ្ម?

រិត ៖ ទេ! ខ្ញុំមិនដែលប៉ះទេ។

ធានី ៖ អត់ដែលប៉ះ?

រិត ៖ ប៉ះពួកវ័យកណ្តាល ពួកយុវជន យុវនារី។

ធានី ៖ ពូបានឃើញ បានដឹង?

រិត ៖ នោះឯង ឃើញដល់យើងដើរទៅដេកទៅអី យើងលើករួច យើងដើរទៅដេកកន្លែងយើង អាកន្លែងភូមិពង្រ។

ធានី ៖ ចឹងកាលពេលពូ ដឹងថាអ្នកណាអ្នករៀបចំធ្វើអាងត្រពាំងថ្ម?

រិត ៖ ខ្ញុំនៅនេះ មិនដឹងរឿង។

ធានី ៖ ទៅដល់?

រិត ៖ ដឹងថាគេឲ្យលើក ឲ្យធ្វើ។

ធានី ៖ ចុះកងតាវ៉ាល់នឹង មានតែកងពូទេ ឬក៏មានតែកុមារទេ ឬមានកងផ្សេងទៀត?

រិត ៖ ទេ! កងផ្សេងវាមានទៀត។

ធានី ៖ មានច្រើន?

រិត ៖ មានច្រើន។

ធានី ៖ អត់ដឹងប៉ុន្មានកងទេ?

រិត ៖ នោះមិនដឹងប៉ុន្មានកងទេ។

ធានី ៖ ប៉ុន្តែគ្រាន់ដឹងថាមានកងកុមារ ហើយនឹងកងអីគេ?

រិត ៖ កងកម្លាំងទី១ ទី២ ទី៣។

ធានី ៖ ចឹងតាវ៉ាល់នឹង គាត់អ្នកគ្រប់គ្រងកងទាំងអស់នឹង កម្លាំងទី១ ទី២ ទី៣?

រិត ៖ នេះតាវ៉ាល់ តាមោង។

ធានី ៖ ធ្លាក់ដល់ត្រពាំងថ្ម?

រិត ៖ ដល់នោះកងផ្សេង ។

ធានី ៖ លែងមានតាវ៉ាល់ តាមោង?

រិត ៖ ហ្នឹងហើយ ។

ធានី ៖ ចុះតាមោងគាត់ទៅណាវិញទៅ?

រិត ៖ មិនដឹងទេ ។

ធានី ៖ ចុះវ៉ាល់ក៏អត់មានដែរ?

រិត ៖ អត់ ។

ធានី ៖ អត់ដឹងទៅណាទេ?

រិត ៖ អត់ដឹងទេ ផុតតែយើងដូចថា ។

ធានី ៖ ចុះអ្នកណាគេអ្នកគ្រប់គ្រងពូវិញ?

រិត ៖ នោះ អាស៊ុយរបូតចប់សព្វថ្ងៃ ។

ធានី ៖ តែស៊ុយនឹង ជាប្រធានក្រុម មិនមែនជាប្រធានកងផង?

រិត ៖ ប្រធានក្រុម ។

ធានី ៖ ប្រធានកងអត់ដឹងទេ ដឹងថាតាស៊ុយនឹងជាប្រធានក្រុម?

រិត ៖ នោះហើយ ដូចថាម៉ាក្រុមយើងចេះ ។

ធានី ៖ អត់ដឹងថាអ្នកណាគេធ្វើទំនប់នឹង អត់ដឹងដែរ?

រិត ៖ មិនដឹងទេ ។

ធានី ៖ ហើយធ្វើពីពេលណាមកពូដឹងទេ?

រិត ៖ អត់ដឹងទេ ។

ធានី ៖ ចុះគេធ្វើចប់ហើយពេលណា?

រិត ៖ ចប់នោះ ឆ្នាំប៉ុន្មានអីប៉ុន្មាន អ្នកណាដឹងទេកាលនោះ ដឹងអ្នកណាចាប់អារម្មណ៍អារឿងចុះៗ ទាំងគេទាំងខ្ញុំ ឲ្យបានចប់ព្រោងប្រៀប ។ អារួចពីទំនប់នោះ ក៏ឲ្យធ្វើស្ពានប្រឡាយខែប្រាំង ខែអីរួច ដល់នោះវៀតណាមវ៉ៃពព្រោងបប្រៀបក៏រត់ចេញ ។

ធានី ៖ រត់ចេញ?

រិត ៖ បាទ!

ធានី ៖ ចុះពូចាំទេ ថាពេលពូធ្វើទំនប់នឹងឆ្នាំប៉ុន្មាន? ហើយពេកឈប់វិញ?

រិត ៖ ដឹងឆ្នាំប៉ុន្មាន ។

ធានី ៖ កាលនឹងដូចថាចូលប៉ុន្មាន ខែប្រាំងប៉ុន្មានដង ខែវស្សា បានពូមកធ្វើនៅទំនប់ត្រពាំងថ្មនឹង?

រិត ៖ ដឹងចូលប៉ុន្មាន ។

ធានី ៖ ព្រោះបើគិតខែប្រាំង ខែវស្សាទៅ យើងធ្វើស្រែប្រាំងបាន៣ដង ស្រែវស្សាបាន៣ដង បានដុត៣ឆ្នាំ?

រិត ៖ នោះឯង សម័យយើងធាក់រហាត់នោះ ។

ធានី ៖ ពេលដែលពូនៅធ្វើជាកង ចឹងដល់ទៅដល់ត្រពាំងថ្មីលែងធ្វើក្នុងកងតាវ៉ាល់ហើយ?

រិត ៖ បាត់ហើយ កងគេផ្សេង បាត់តាវ៉ាល់ ។

ធានី ៖ ហើយអត់ដឹងថាគាត់ទៅណា?

រិត ៖ អឺ!

ធានី ៖ ហើយមានអ្នកផ្សេងមកជំនួស?

រិត ៖ មកជំនួសផ្សេង ។

ធានី ៖ អ្នកនឹងមកពីណា ពូដឹង?

រិត ៖ ដូចខ្ញុំថាចឹង មិនដឹងថាតាមោង តាវ៉ាល់ មិនដឹងមកពីណាពីណៃ យើងអត់ស្គាល់ទេ ។

ធានី ៖ ដល់ពេលអ្នកមកពីក្រោយទៀត ក៏លែងស្គាល់ទៀត?

រិត ៖ បាទ!

ធានី ៖ ដែលពូឈ្មោះយាយថែម?

រិត ៖ យាយថែម ពូ ។

ធានី ៖ យាយថែមនឹងពីណាគេ?

រិត ៖ អ្នកនិរតី ។

ធានី ៖ គាត់មកធ្វើអីគេ?

រិត ៖ ទេ! កាលនោះ គាត់កាន់ក្តាប់ គាត់នៅភ្នំលាភ ។

ធានី ៖ ហើយគាត់នឹងជាអ្នកណាគេ?

រិត ៖ មិនដឹងអ្នកមកពីណាពីណៃ ឈ្មោះគាត់ស្គាល់ ។ យាយថែម តាក្រក់នេះ ម៉ាសេរីគាត់ ។ តាក្រក់នៅត្រង់នេះ ។

ធានី ៖ គាត់នៅរស់ទេ តាក្រក់នឹង?

រិត ៖ តាក្រក់នោះស្លាប់ហើយ ។

ធានី ៖ តាក្រក់នឹង គាត់ធ្វើការជាមួយយាយថែម?

រិត ៖ បាទ! យាយថែមគាត់នៅនោះ នៅខាងភ្នំលាភ ។ តាក្រក់គាត់នៅនេះ ផ្លូវឡើងភ្នំ ។

ធានី ៖ ហើយពួកគាត់មានផាវជាអីគេ បានក្ដាប់នៅនឹង?

រិត ៖ គាត់នោះ

ផាវគាត់នោះមកក្ដាប់អារឿងប្រជាជនយើងដឹកនាំធ្វើស្រែធ្វើចំការធ្វើភ្លឺនេះឯង ។

ធានី ៖ ជំនួសតាមោង តាវ៉ាល់នឹង ឬយ៉ាងម៉េច?

រិត ៖ ម៉ាសេរីគ្នាទាំងអស់នឹង ។

ធានី ៖ ជំនួសពួកគាត់នឹង?

រិត ៖ ទេ! ដូចថាម៉ាផ្នែកៗគ្នានឹង ។

ធានី ៖ ចង់និយាយថា មើលទៅបើសិនជាពូគិត ថាមោង ហើយតាវ៉ាល់នឹងតូចជាងយាយថែម ហើយនឹងតាក្រក់នឹង ឬតាក្រក់នឹងធំជាងយាយថែម?

រិត ៖ មិនដឹងថាអ្នកណាតូច អ្នកណាធំទេ ។

ធានី ៖ ប៉ុន្តែសុទ្ធតែអ្នកគ្រប់គ្រងដូចគ្នា?

រិត ៖ នៅគ្រប់គ្រងដូចគ្នាទៅចុះ ។

ធានី ៖ អត់ដឹង?

រិត ៖ កាលនោះដូចថាវ័យកណ្ដាលដូចគ្នា អ្នកណាហ៊ានសួរ ។

ធានី ៖ ហើយបានឃើញយាយថែមដែរ រូបរាងគាត់ម៉េច?

រិត ៖ ខ្ញុំថាមិនឃើញ មាឌល្អិតខ្មៅ យាយថែម ។

ធានី ៖ គាត់មានគ្រួសារទេ?

រិត ៖ ទេ! គាត់ចាស់ហើយកាលនោះ គាត់មាននិយាយ គាត់ស្លៀកសំពត់ខ្មៅ ថ្ងៃណាគាត់ស្លៀកសំពត់ខ្មៅចងក្បិនក៏មាន ចាស់ហើយ ។

ធានី ៖ គាត់ចាស់អាយុប៉ុន្មានដែលកាលនឹង?

រិត ៖ កាលនោះ បើខ្ញុំស្មានមើលតាមសាច់ឈាមគេ អាយុបែប៤០លើសហើយ ចាស់ហើយ មិនមានសម័យនិរតី ចូល៤០លើសហើយ គាត់ចាស់ដែរ សព្វថ្ងៃនៅ ។

ធានី ៖ ដឹងថានៅរស់?

រិត ៖ ហ្នឹងហើយដឹងថានៅរស់ ។

ធានី ៖ ដឹងនៅណា?

រិត ៖ សព្វថ្ងៃចុះទៅបៀតកន្លែងតាម៉ុក ។

ធានី ៖ គាត់នៅរស់តើ យាយថែម ។

រិត ៖ នៅរស់ ពីដើមមិញ សព្វថ្ងៃដូចពាក្យសេកពាក្យសត្វ ថាគាត់ប្រធានឃុំ ។

ធានី ៖ ចា៎! ក្រុមប្រឹក្សាឃុំ ។

រិត ៖ នាងស្គាល់គាត់ដែរចុះ?

ធានី ៖ ខ្ញុំទៅលេងគាត់ទៀត ។

រិត ៖ មាឌល្អិតខ្មៅទៀត កាលនោះ ។

ធានី ៖ អត់ផង ឥឡូវគាត់រៀងជ្រះសំបុរជាងមុន ខ្ញុំមិនដឹងថាម៉េច គាត់សំបុរប្រហែលៗខ្ញុំ ។

រិត ៖ គាត់ស្រណុក ។ សព្វថ្ងៃ គាត់អាយុប្រហែលប៉ុន្មាន ស្មានមើល ។

ធានី ៖ អត់ចាំ ។

រិត ៖ ឃើញរូបគាត់ ស្មានមើលអាយុគាត់?

ធានី ៖ ឃើញគាត់មានកម្លាំងមាំ គាត់ដើរព្រិល គាត់ធ្វើអីៗបានគ្រប់សព្វ ។

រិត ៖ សុខភាពគាត់ល្អ ។

ធានី ៖ និយាយទៅចង់មាំជាងក្មេងៗឥឡូវ ។

រិត ៖ ល្បី គាត់ពូកែ ។

ធានី ៖ ពូកែយ៉ាងម៉េច?

រិត ៖ ទេ! គេនិយាយពាក្យសេកពាក្យសត្វ មានកំបាំងរឿងអី ពូកែគាត់ ។

ធានី ៖ កាលសម័យនឹង?

រិត ៖ ទេ! កាលសម័យសង្គ្រាម សព្វថ្ងៃដូចគ្នា ។

ធានី ៖ អត់ទេ ពូដឹងទេថា កាលសម័យខ្មែរក្រហមដែលពូបានធ្វើទំនប់នឹង ដឹងថាគេនិយាយអីខ្លះពីគាត់ថាយាយថែម ជាមនុស្សម៉េច គាត់កាច គាត់ស្លូត?

រិត ៖ ទេ! អារឿងគាត់ម៉ាផ្នែកៗ ដូចតាក្រក់ ។

ធានី ៖ គ្រាន់តែពូយាយថែម តាក្រក់?

រិត ៖ ខ្ញុំស្គាល់ កាលនោះខ្ញុំទៅកាប់ធាងដូងថាទៅរៀបទំនប់រៀបអី ពួកគាត់នឹងឯងនាំទៅឲ្យកាប់ភូមិនេះ ទៅកាប់នេះដូងនេះ ថាកាប់យកទៅបាំង ។

ធានី ៖ កាប់ធ្វើអីគេ?

រិត ៖ ទៅបាំងទំនប់កុំអីខ្យល់វានេះ ទឹកវាវ៉ៃមក ។

ធានី ៖ ចឹងយាយថែមហើយនឹងតាក្រុកនឹង ជាអ្នកបញ្ជាឲ្យពូ?

រិត ៖ ទេ! អ្នកផ្សេងៗនាំមកដូចថាទាក់ទងឲ្យគាត់បញ្ជាប្រាប់ គាត់ទៅកន្លែងផ្ទះគាត់នោះ សព្វថ្ងៃគាត់ធ្វើអស់ហើយអាផ្ទះនោះ ខ្ញុំស្គាល់អាកន្លែងបាតផ្ទះទៀត ។

ធានី ៖ ទាក់ទងអ្នកណាគេ បានគេទៅស្គាល់យាយថែម?

រិត ៖ ទាក់ទងប្រធានភូមិយាយថែម គាត់ប្រាប់ ។

ធានី ៖ យាយថែមទាក់ទងប្រធានភូមិ ឬប្រធានភូមិទាក់ទងយាយថែម ដើម្បីមកជួបពូ?

រិត ៖ ប្រធានក្រុមពួកខ្ញុំនេះឯងទាក់ទង ។

ធានី ៖ ទៅទាក់ទងយាយថែម ប្រាប់ថាដោយសារទំនប់យើងទឹកខ្លាំង?

រិត ៖ ហ្នឹងហើយសុំធាងដូងធាងអី បានថាឲ្យកាប់ឲ្យអី កាលនោះសុទ្ធតែស្នើសុំគេទាំងអស់ តែធ្វើអីក៏ស្នើសុំដែរ ។

ធានី ៖ ចឹងកាលនឹងសុំយាយថែមផង សុំតាក្រុក់ផង?

រិត ៖ បាទ!

ធានី ៖ ហើយតាក្រុក់នឹង រូបរាង មាឌគាត់ម៉េច?

រិត ៖ មាឌល្អិត ។

ធានី ៖ មាឌល្អិតដែរ ហើយមាឌធំ ហើយតូច?

រិត ៖ ឡើងជិះតែសេះ ។

ធានី ៖ ខ្មៅស ខ្ពស់?

រិត ៖ ខ្មៅ មាឌល្អិតដែរ ។

ធានី ៖ អត់ដឹងថាគាត់នៅរស់ ឬស្លាប់ទេ?

រិត ៖ ស្លាប់ហើយ នៅយូរហើយស្លាប់ ។

ធានី ៖ ម៉េចបានដឹងថាស្លាប់?

រិត ៖ ស្លាប់កាលនោះ ខ្ញុំថាបាត់ប៉ិតូៗ រួចបាត់ទាំងអស់ ។

ធានី ៖ ចឹងប៉ិ តូ នឹងគាត់ជាប្រធានកងកុមារពូនឹង បានបាត់ជាមួយគ្នានឹង?

រិត ៖ ហ្នឹងហើយ ដូចថាអ្នកវ៉ៃរបបនឹង ។

ធានី ៖ តែយាយថែមនៅវិញ?

រិត ៖ យាយថែមអត់អីទេ ។

ធានី ៖ តែបាត់តាក្រក់ បាត់ខ្លួនទៅ?

រិត ៖ បាត់មែន ។

ធានី ៖ បាត់តាក្រក់ យាយថែម គាត់ធ្វើការជាអី?

រិត ៖ ភាគច្រើនគាត់ធ្វើការនៅលើចឹង ។

ធានី ៖ ជំនួសតាក្រក់វិញ?

រិត ៖ មិនដឹងជំនួសអី ។

ធានី ៖ គាត់ធ្វើការទាំងអស់?

រិត ៖ ហ្នឹងឯង គាត់ដើរមើលគ្រប់គ្រងទាំងអស់ ។

ធានី ៖ អត់ដឹងថាគាត់ស្លុតហើយកាចទេ?

រិត ៖ អត់ដឹង គាត់ ។

ធានី ៖ ពេលពូធ្វើការនៅទំនប់នឹង ពូដឹងថា ទំនប់ត្រពាំងថ្មនឹង មានមកកំពស់ប៉ុន្មានម៉ែត្រ ខ្នងទទឹងវា ។ មិញពូប្រាប់ថា ខ្នងវាទទឹង៥ម៉ែត្រ?

រិត ៖ ខ្នងវាដឹងថា៥ធំ កំពស់វាក៏ខ្ពស់ ។ ខ្ញុំសង្ស័យ ៣ម៉ែត្រហើយ បើ៣ម៉ែត្រចុះអត់មានទេ ។

ធានី ៖ ម៉េចចឹង?

រិត ៖ កំពស់តួអាងតូចណាស់ហា៎ ។

ធានី ៖ ចុះជំរៅវាប៉ុន្មាន បើតួវា?

រិត ៖ ជំរៅបាតប្រឡាយនោះ?

ធានី ៖ ហ្នឹងហើយ ។

រិត ៖ បាតប្រឡាយ៣ម៉ែត្រ ។

ធានី ៖ ៣ម៉ែត្រចុះ ៣ម៉ែត្រឡើង?

រិត ៖ នោះឯង ។

ធានី ៖ ៦ម៉ែត្រ ធំ?

រិត ៖ ធំណាស់ ។

ធានី ៖ ហើយបណ្តោយដូចថាម៉ាអាងជុំវិញនឹង ដឹងថាប៉ុន្មានម៉ែត្រ?

រិត ៖ អូ! មិនដឹងទេ មិនដឹងប៉ុន្មាន ។

ធានី ៖ ចុះពូដឹងថាមនុស្សប៉ុន្មាននាក់ធ្វើការនៅនឹង?

រិត ៖ មិនដឹងប៉ុន្មាននាក់ទេ វាច្រើនរាប់ពាន់នាក់ ។

ធានី ៖ ហើយធ្វើប៉ុន្មានឆ្នាំ?

រិត ៖ ខ្ញុំកាលនឹងនៅនេះម៉ាខែកន្លះ ។

ធានី ៖ ក្រៅពីនឹងអត់ដឹងទៀតទេ?

រិត ៖ នោះឯង ។

ធានី ៖ ចុះពូដឹងថាទំនប់នឹង ដឹងថាគេកសាងពីឆ្នាំណាដល់ឆ្នាំណា?

រិត ៖ ដូចខ្ញុំថាចឹង ខ្ញុំកាលនោះមានទៅគិតគូអារឿងឆ្នាំប៉ុន្មាន ។

ធានី ៖ ដូចថាដឹងថាធ្វើប៉ុន្មាន?

រិត ៖ តាមខ្ញុំទៅធ្វើ ដូចមិនបាន៣ខែ ។

ធានី ៖ មិនបាន៣ខែ ហើយទាំងអស់?

រិត ៖ វានៅដែរ ដូចថានៅកម្រិតទី១ កងស្រួចគេ វាដើរសំអាត មើលត្រង់ណាដេរដត ត្រង់ណាមិនល្អអី គេបំពេញ ។ ពួកខ្ញុំគេដកមកឲ្យធ្វើកន្លែងទំនប់ស្រែប្រាំង ស្រែអីផ្សេងៗចុះមកក្រោម ។

ធានី ៖ និយាយទៅយើងបាននៅម៉ារយៈ យើងអត់ដឹងថា?

រិត ៖ នោះឯង ម៉ាយៈៗយើងអត់កំណត់ទេ ។

ធានី ៖ ចឹងពូអត់បានចូលក្នុងការសម្ពោធន៍អាងនឹង ដឹងគេមានសម្ពោធន៍អាងនឹង?

រិត ៖ មាន កាលនោះ គេប្រេជ្ញាចិត្ត ដូចថាយើងចាប់ដៃយើងធ្វើរួចម៉ាអាងនេះ ចាប់ដៃគ្នាហើយគេជប់លៀង គេវៃជួនវៃអីជប់លៀងគេសម្ពោធន៍ គេប្រេជ្ញាចិត្តប្រធានកងប្រធានអីគ្នាគេនឹង មានប៉ុននោះឯង ។

ធានី ៖ គេប្រេជ្ញាចិត្ត គេធ្វើម៉េចខ្លះទៅ?

រិត ៖ ប្រេជ្ញាចិត្តដូចថាប្រវត្តិគេតស៊ូ គេបានជ័យជំនះគេ ក្នុងម៉ាមុខព្រួញ ម៉ាវគ្គៗគេ ។

ធានី ៖ តែចង់និយាយថា ម៉ាអាងហើយអស់នឹង គេមានចាប់ដៃគ្នាធ្វើចឹងអត់?

រិត ៖ ធ្វើតើ ។

ធានី ៖ ធ្វើអាងហើយអស់ហើយបានគេធ្វើចឹង?

រិត ៖ នោះឯង គេជប់លៀង ។

ធានី ៖ មានមនុស្សប៉ុន្មាននាក់?

រិត ៖ អូ! ច្រើនណាស់ ចាប់ដៃគ្នាអង្គុមេទិញមួយៗ ច្រើនណាស់ រាប់ពាន់នាក់ ។

ធានី ៖ ហើយកាលនឹងអ្នកណាគេចូលរួមពូដឹងទេ?

រិត ៖ អូ! កាលនោះសួរខ្ញុំដឹងម៉ាដឹង បានម៉ាស្គាល់បានម៉ាឃើញប៉ុននឹង ។

ធានី ៖ គេធ្វើម៉េចខ្លះពូដឹង? ដំបូងពូថាគេចាប់ដៃគ្នា មុនដំបូងមាននិយាយ?

រិត ៖ យើងនិយាយដែលយើងប្ដេជ្ញាចិត្តថា យើងធ្វើការឲ្យល្អកុំឲ្យខុសសីលធម៌ខុសអី យើងធ្វើបម្រើអង្គការយើងចេះចុះ ។ សម័យកាលនោះគេចេះតែលើកអង្គការហើយ ។

ធានី ៖ តែពូកាលនឹងគេចូលរួមសម្ពោធនឹង ឬអាងផ្សេង អាងត្រពាំងថ្មនឹង ឬអាងណា ដែលពូបានចូលរួម?

រិត ៖ ខ្ញុំនេះបាននៅរន្ទះបាញ់នេះ ។

ធានី ៖ ម៉េចបានគេដាក់ឈ្មោះរន្ទះបាញ់នឹង?

រិត ៖ ឈ្មោះគេពីដើមមកចឹងឯងដូចត្រពាំងថ្ម ។

ធានី ៖ ចឹងពូអត់បានចូលរួមសម្ពោធន៍អាងត្រពាំងថ្មទេ?

រិត ៖ ទេ! អត់ទេអានោះខ្ញុំដកផុត ដកមកខាងស្រែប្រាំង ធ្វើទំនប់ស្រែប្រាំង លើកទទឹង២ម៉ែត្របណ្ដោយរាប់ហ្វាង ប្រើនោះធ្វើស្រែប្រាំង ។

ធានី ៖ នៅណាវិញ ស្រែប្រាំង?

រិត ៖ ត្រពាំងថ្ម អានឹងធ្វើតូចៗនេះទេ អានោះស្រែប្រាំងគេធ្វើមិនធ្វើមិនដឹងទេ យើងធ្វើគ្រាន់ដឹងថាចល័ត គេថាខ្លះកម្លាំងគេស្នើសុំទៅ យើងធ្វើឲ្យគេ ។ ដូចថាយើងកម្លាំងស៊ីន ។

ធានី ៖ ហើយការហូបចុកម៉េចដែរនៅត្រពាំងថ្ម ដូចពូនិយាយប្រាប់មុនដំបូង?

រិត ៖ ពិបាក ដល់ត្រពាំងថ្មនឹង មិនពិបាកមិនសូវអីទេ ត្រពាំងថ្មគិតថាបបរត្រកួន ស្លត្រកួន ។

ធានី ៖ បបរម៉ាថ្ងៃប៉ុន្មានដង?

រិត ៖ ម៉ាថ្ងៃ២ដង ព្រឹកល្ងាច ។

ធានី ៖ ម៉ាថ្ងៃ២ដងគឺ ព្រឹក ហើយ ល្ងាច មិនមែនថ្ងៃត្រង់?

រិត ៖ អត់ទេ បើថ្ងៃត្រង់ជង៣ដង ។

ធានី ៖ ចឹងការងារយ៉ាងម៉េចទៅ?

រិត ៖ ការងារគេនេះ ធ្វើដូចតែយើងចេះឯង ដូចថាយើងកំណត់២ម៉ែត្រគឺបកន្លះរួចក៏ ។

ធានី ៖ ដូចថាធ្វើពីម៉ោងប៉ុន្មានទៅម៉ោងប៉ុន្មាន?

រិត ៖ ពីម៉ោងក្រោកៗធ្វើពីយប់ ។

ធានី ៖ តាំងព្រលប់ម៉ោងប៉ុន្មាន?

រិត ៖ ម៉ោង៣ ម៉ោង៤ ។

ធានី ៖ ចឹងពូប្រាប់ថា ធ្វើការពីយប់ម៉ោង២ ម៉ោង៣?

រិត ៖ ក្រោយធ្វើ ។

ធានី ៖ ហើយដល់ស្មានណា?

រិត ៖ ម៉ោង១០ បើមិនរួច ចាប់ពីម៉ោង១ចាប់ផ្ដើមធ្វើទៀត អានឹងម៉ោង១២យើងវាមិនទៀងទេ ពីសម័យនោះដូចយើងកំណត់ម៉ោង ។

ធានី ៖ ដល់ពេលយប់ស្មានណាទៅ ម៉ោង១១?

រិត ៖ ថ្ងៃណាបើមិនរួចទេណា ដូចថាយើងបាយរួច បើសិនណាយើងមិនរួច ធ្វើឲ្យគេម៉ោង៥-៦យប់ក៏មាន ម៉ោង៧យប់ក៏មាន ។

ធានី ៖ អស់ត្រឹមម៉ោង៧យប់?

រិត ៖ នោះហើយ ។

ធានី ៖ តែដល់ពេលពូធ្វើម្ដងៗមានគេជួយធ្វើដែរកុមារៗ?

រិត ៖ ជួយដូចថាកម្លាំងយើងត្រូវគ្នា យើងមានកម្លាំងយើងជួយគ្នាទៅ ។ បើយើងមិនមានអ្នកណា មិនសូវពេញចិត្ត ក៏ដាក់តែអំរែក ដេកក្នុងអន្ទង ចាំគ្នាទាល់តែរួច ហៅគ្នារួចឡើងទៅទាំង អស់គ្នា ។

ធានី ៖ ចឹងយើងអត់អាចរៀបថាអ្នកណាឡើងមុន ឡើងក្រោយ នៅកន្លែងគេអត់បាន?

រិត ៖ ទេ! អាខាងណាមិនមានចិត្តជួយក៏ឡើងទៅមុនទៅ ។

ធានី ៖ ឡើងទៅៗកន្លែងគេគេង កន្លែងស្នាក់នៅ?

រិត ៖ កន្លែងយើងស្នាក់នៅទាំងអស់គ្នា ។

ធានី ៖ ហើយបបរនឹង បបរជាមួយត្រកួននឹង ដាក់ប៉ុន្មាន?

រិត ៖ មិនបានស្មើអាចានគុយទាវយើងអាតូច ។

ធានី ៖ ចានកូម?

រិត ៖ នោះឯង ចានគុយទាវយើង ។

ធានី ៖ ហើយម៉ាចាននឹង គឺម៉ាពេលនឹង?

រិត ៖ ម៉ាពេល ។

ធានី ៖ ហើយបបរ មានដូចបបរយើងរាល់ថ្ងៃទេ?

រិត ៖ បបរមិនស្មើបបរជ្រូក ។

ធានី ៖ គេដាក់អង្ករយើង ឬក៏?

រិត ៖ អង្ករយើងធម្មតា តែវាតិចៗមែនទែន ។

ធានី ៖ ចឹងពូបានអីហូបទៅ?

រិត ៖ ដូចខ្ញុំថាចឹង ទៅស្ទុះគុំ ស្ទុះខ្ទៅ ខ្យងលួចយកមកដុត ។

ធានី ៖ លួចទៅ?

រិត ៖ លួចនោះហើយ ។

ធានី ៖ ដែលមានគេតាមទាន់ទេ?

រិត ៖ ទេ! ប៉ះណាគេតាមទៅ ប៉ះណាគេដឹងចុះ វាពួកកុមារវាមិនសូវអីប៉ុន្មានទេ ។

ធានី ៖ អាចបាន?

រិត ៖ ដូចថាគេអនុគ្រោះខ្លាំង បើថាចាប់ពីវ័យកណ្ដាល កម្លាំងទី១ យុវនារីនេះមិនបានទេ ។

ធានី ៖ បើគិតទៅពូអាយុ១៨ ១៩នឹង នៅពេលធំងជា តែគេមិនហៅយុវជនទេ?

រិត ៖ ពេញ អត់ទេ នៅ ។

ធានី ៖ នៅកងកុមារ?

រិត ៖ នៅកងកុមារ ។

ធានី ៖ ពូដឹងថាហេតុអីបានគេកសាងទំនប់នឹងឡើង?

រិត ៖ មិនដឹងរឿងទេ អារឿងប្រវត្តិកសាងទំនប់ អារឿងធ្វើប្រឡាយបេះចុះ មិនដឹងរឿងស្រាប់តែគេប្រើឲ្យធ្វើ គិតពីធ្វើ ។

ធានី ៖ ចុះពូមានឃើញប្រជាជនថ្មីអី យើងទៅធ្វើនៅនឹងច្រើន?

រិត ៖ ទេ! ប្រជាជនថ្មី ប្រជាជនចាស់អី ធ្វើជាមួយគ្នាទាំងអស់ ។

ធានី ៖ តែមើលទៅឃើញពួកគាត់ពិបាកទេ?

រិត ៖ ដូចតែគ្នា ដូចថាយើងប្រជាជនចាស់ស្រួល ប្រជាជនថ្មីយ៉ាប់មិនមានទេ ពិបាកដូចតែគ្នា ។

ធានី ៖ លើកលែងតែកងកុមារទេ ដែលយើងមើលទៅអស់សូវប៉ុន្មាន?

រិត ៖ អត់សូវអីប៉ុន្មាន អារឿងស្លាប់ក៏មិនសូវស្លាប់ប៉ុន្មានទេ ។

ធានី ៖ ហេតុអីពូ ព្រោះកុមារធម្មតាគេឲ្យធ្វើចឹង ដូចពូនិយាយចឹងថាដួនកាលពេលខ្លះ ឡើងវាឡើង?

រិត ៖ ចុះដូចថាវាស្ទុះអស់រលីងហើយ វាហេវហត់ពេញធំងហើយ ។

ធានី ៖ អត់អីទេ អត់ស្លាប់ទេ?

រិត ៖ អត់ស្លាប់ទេ មានខ្លះឈឺស្លាប់ក៏មានអីក៏មាន ។

ធានី ៖ មានច្រើនទេ ឈឺស្លាប់?

រិត ៖ មានខ្លះដែល តែមិនដូចវ័យកណ្តាល ។

ធានី ៖ ពេលដែលពូធ្វើការនៅនឹងបានម៉ាខែកន្លះ បានពូត្រឡប់មកខាងធ្វើស្រែប្រាំង?

រិត ៖ នោះឯង អាប្រឡាយស្រែប្រាំង ប្រឡាយស្រែ ។

ធានី ៖ ហើយធ្វើការតែប៉ុននឹងរហូតដល់ពេលណា?

រិត ៖ វៀតណាម ។

ធានី ៖ កាលនឹងពូនៅណា វៀតណាមចូល?

រិត ៖ ខ្ញុំនៅមកធ្វើនេះទៀត មកធ្វើនៅព្រែកយើងនេះ ។

ធានី ៖ ចឹងមកភូមិវិញ មកនៅភូមិបណ្តោយ?

រិត ៖ នោះឯង ដល់ពួកខ្មែរក្រហមរត់ចេញទៅ ក៏យើងរត់មកនៅជាមួយម៉ែឪយើង ។

ធានី ៖ ហើយនៅភូមិយើងម៉េចដែរ មើលទៅ?

រិត ៖ ទេ! មានអីធម្មតា ។

ធានី ៖ អត់មានផ្ទះសម្បែងរុះរើអីណា?

រិត ៖ មាន ផ្ទះខ្ញុំគេរើសអស់សម័យប៉ុល ពត ។ បើនៅៗផ្ទះសព្វថ្ងៃ រើមកនៅជាមួយបងប្អូនទល់សព្វថ្ងៃ ។

ធានី ៖ ហើយដីស្រែយើង នៅរបស់យើងដដែល?

រិត ៖ ទេ! សព្វថ្ងៃចែក ។

ធានី ៖ តែពេលពូមកវិញចែកគ្នា?

រិត ៖ ចែកគ្នា ។

ធានី ៖ ដីស្រែពូចាស់ៗអស់ហើយ?

រិត ៖ វានៅដែរ ដូចឧទាហរណ៍ថា មើលគ្នាទៅពីភ្នំពេញនៅអី ដែលគ្នាមិនបានទៅភ្នំពេញ គ្នាមាន ដីណា បើមិនចែកគ្នា ។ ចែកគ្នាស្មើទាំងអស់ ដូចថាម៉ាគ្រួសារម៉ាហិចតាកន្លះៗ ។

ធានី ៖ ចែកគ្នាទាំងអស់ចឹង?

រិត ៖ បាទ! នោះឯង ។

ធានី ៖ ពេលដែលពូរស់នៅ កាលនឹងមានការលំបាកអីអត់ទេ ពេលសម័យ៧៩មកវាមានប្រទាញប្រទុងគ្នារវាងខ្មែរក្រហមជាមួយ?

រិត ៖ ទេ! កាលនោះវាមានចឹងឯង វៃគ្នារត់លូនតាមនេះ ។

ធានី ៖ ហើយអត់សូវអីទេ?

រិត ៖ អត់សូវអីទេ ។

ធានី ៖ យើងហូបចុកអីបាន?

រិត ៖ គ្រប់គ្រាន់ យើងចូលមកដល់នោះហើយ សម័យកាលនោះគ្រប់គ្រាន់ហើយ ។

ធានី ៖ កាលនឹងពូមានអារម្មណ៍ម៉េចដែរទៅ?

រិត ៖ ទេ! ខ្ញុំមានអារម្មណ៍ថា វាសប្បាយដែរ ដល់យើងមានស៊ីគ្រប់គ្រាន់ហើយ មានពិបាក ។

ធានី ៖ ហើយដែលគិតដល់រឿងចាស់ ដែលពូធ្លាប់ឆ្លងកាត់ ដែលពូជាកុមារ បើគិតទៅដូចថាក្មេង ឥឡូវ បើឲ្យនិយាយរឿងនឹងអី ខ្ញុំនៅកុមារដូចគ្នាធ្វើចឹង?

រិត ៖ អឺ! សព្វថ្ងៃនិយាយប្រាប់វាអត់ជឿទេ មិនជឿងយើងទេ ថាយើងនិយាយកុហកចេះចុះ គ្មានអ្នកទៅវៃមនុស្សចោលណាសម័យប៉ុលពត ។

ធានី ៖ ប៉ុនពូធ្លាប់និយាយរឿងដូចថាពូនៅជាកុមារកាលសម័យនឹងដែរ?

រិត ៖ ប្រាប់ ។

ធានី ៖ ហើយវាថាម៉េចទៅ?

រិត ៖ ទេ! បើកូនខ្ញុំមិនថាអីទេ បើខ្លះណាថាជិទង់ៗ ដូចថាខ្ញុំថាវានិយាយលេងផង និយាយប្រាប់ វាមិនសូវជឿ ។

ធានី ៖ អត់ជឿថាមានប្រវត្តិចឹង?

រិត ៖ បាទ! នោះឯង ។

ធានី ៖ ចុះពូដែលធ្លាប់ឮរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?

រិត ៖ ទេ! ស្ដាប់តាមប៉ុស្ដិ៍តាមអី ឮរាល់ថ្ងៃនេះ តាប៉ុស្តិ៍នោះ បើប៉ុស្តិ៍បានឮរាជ្យ បើនេះម្ដងៗ ។

ធានី ៖ ស្ដាប់តាមដានរាល់ថ្ងៃ?

រិត ៖ ខ្ញុំនោះ អត់ទេ ស្ដាប់ឮទៅមើលផ្ទះក្មួយ ។

ធានី ៖ តែដឹងថារាល់ថ្ងៃគេកាត់ទោសអ្នកណាគេខ្លះហើយ?

រិត ៖ តាឌុចណាទេ ។

ធានី ៖ ដឹងថាកាត់ទោសតាឌុច?

រិត ៖ នោះឯង ។

ធានី ៖ ពូបានដឹងរឿងសាលក្រមរបស់ឌុច ដែលគេចាត់ទោសឲ្យគាត់ជាប់៣៥ឆ្នាំ ហើយកាត់ទោស ចុះឡើងនៅសល់១៩ឆ្នាំវិញទេ?

រិត ៖ ខ្ញុំមិនសូវតាមដាន អារឿងកាត់ទោសកាត់អី មិនដឹងជាគាត់កាត់ទោសដាក់ប៉ុន្មានៗទៀត មិនដឹង ។

ធានី ៖ គ្រាន់ដឹងថាមានតុលាការកាត់ទោស?

រិត ៖ បាទ! នោះឯង ចុះបើម្ដាយក្មេកខ្ញុំដែរ នៅទៅដែរកាត់ទោស គេឲ្យប្រធានឃុំនេះ ឪពុកមាខ្ញុំ នាំម៉ែឪខ្ញុំឡើងទៅកាត់ទោស ទៅភ្នំពេញ មើលគេកាត់ទោសកាត់អី ទៅលេងបងប្អូនគាត់នៅភូមិស្អីនោះឆ្ងាយពីភ្នំពេញទៅទៀត ថានៅជាង១០០គីឡូទៀត ។

ធានី ៖ នៅខេត្តអីគេ?

រិត ៖ អង្គស្នួលនឹងឯង ។

ធានី ៖ អង្គស្នួលខេត្តកណ្ដាល?

រិត ៖ នោះឯង ថាចំមិនត្រូវអង្គស្នួលទេ នៅគិតទៅចូលជាង១០០គីឡូ ។

ធានី ៖ មិនដល់ទេ ពីព្រោះអីពីភ្នំពេញទៅដល់កំពង់ស្ពឺ១០០ អត់ដល់១០០ទេ តែ៤០គីឡូ ។

រិត ៖ ខ្ញុំមិនដែលនេះទេ បងប្អូនមកលេង ឲ្យខ្ញុំទៅលេងអី ។

ធានី ៖ ពីយល់ម៉េចដែរ ចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹង?

រិត ៖ ខ្ញុំនិយាយឡើងប្រជាជនចេះ វាធម្មតា កាត់ទោសម៉េច ក្នុងច្បាប់វិន័យគេ ខ្ញុំអ្នកស្រុកអ្នកស្រែក៏ធ្វើទៅ ។

ធានី ៖ គិតថាវាមានប្រយោជន៍អត់ការកាត់ទោស បង្កើតតុលាការកាត់ទោសអ្នកអស់នឹង?

រិត ៖ ទេ!កាត់ទោស តាមតុលាការនឹងវាត្រឹមត្រូវហើយ ប៉ុន្តែដូចខ្ញុំអ្នកស្រុកអ្នកស្រែ គេដើរទៅយ៉ាងណាទៅចុះ បណ្ដោយៗគ្នា ។ ដូចថាយើងរស់នៅសង្គមណា យើងគាំទ្រសង្គមនោះហើយ ។

ធានី ៖ ចឹងពូមានអីចង់បន្ថែមទៀតទេ នូវអ្វីដែលខ្ញុំអត់បាននិយាយ?

រិត ៖ មិនមានអីទេ មិនមានស្អីបន្ថែមទៀតមិនមាន ។

ធានី ៖ ចឹងអរគុណពូច្រើន ។

រិត ៖ បាទៗ ។

«ចប់»